ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ
# របស់ធនាគារ វីង (ខេមបូឌា) ម.ក

INTERNAL AUDITING TO FINANCIAL STATEMENTS
FOR WING BANK (CAMBODIA) PLC

**ជំនាញ: សវនកម្ម**

**រៀបរៀងដោយ៖ លន់ សុខថា**

**អត្តលេខ:** MAPMR20/002

**ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤**

ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ វីង (ខេមបូឌា) ម.ក

INTERNAL AUDITING TO FINANCIAL STATEMENTS FOR WING BANK (CAMBODIA) PLC

ជំនាញ: សវនកម្ម

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឌិម

បេក្ខបណ្ឌិត យ៉ាក ទុទ្ធី

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

**ប្រធានបទ៖ ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ វីង (ខេមបូឌា) ម.ក**

សាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

សាស្ត្រាចារ្យណែនាំ

បណ្ឌិត កង ឱម

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ
ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញសវនកម្ម នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល២ឆ្នាំ សិក្សារួចមក ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម គណនេយ្យ ពន្ធ ជាពិសេសយល់ច្បាស់ថាជំនាញសវនកម្ម គឺជាជំនាញមួយដ៏មានសារៈសំខាន់ សម្រាប់តម្រូវការស្ថាប័នទាំងអស់ មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន វិទ្យាស្ថានក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបាន ជាពិសេសនោះគឺមុខវិជ្ជាសវនកម្ម។ សវនកម្មគឺជាពាក្យមួយដែលប្រជាជនមួយចំនួនធំក្នុងប្រទេសជឿនលឿន នឹងប្រទេសកំពុងអភិវឌ្ឍន៍លើពិភពលោកបានទទួលស្គាល់បានយល់ដឹងអត្ថន័យរបស់វាជាទូទៅ។ ហើយនៅក្នុងនោះក៏មានប្រទេសកម្ពុជាយើងមួយផងដែរ ដែលមានប្រជាជនភាគច្រើនបានយល់ដឹងពីវា បន្ទាប់ពីបញ្ចប់ភ្លើងសង្គ្រាមអស់រយៈពេលកាលពាផ្ទាំជាង។ នៅក្នុងការស្តារប្រទេសនិងអភិវឌ្ឍន៍ប្រទេសឱ្យបានរីកចម្រើន ដូចបណ្តាលប្រទេសជឿនលឿននានានៅលើសកលលោក រាជរដ្ឋាភិបាលក៏បាននឹងកំពុងប្រកាន់យកប្រព័ន្ធបច្ចេកវិទ្យាហរិញ្ញវត្ថុឌីជីថល និងប្រព័ន្ធទីផ្សារសេរី ហើយក៏បានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើនដើម្បីទាក់ទាញអ្នកវិនិយោគទុនក្នុង និងក្រៅប្រទេសមកបណ្តាក់ទុនក្នុងស្រុកដើម្បីជួយលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិឱ្យកាន់តែរីកចម្រើនបានរហូតដល់សព្វថ្ងៃនេះ។ ការវិវត្តន៍សេដ្ឋកិច្ចជាតិបានមកពីកំណើន និងភាពជោគជ័យប្រតិបត្តិការលើអាជីវកម្ម អង្គភាពស្ថាប័នរដ្ឋ និងឯកជនអង្គការក្រៅរដ្ឋាភិបាល។

ក្នុងនោះដែលការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល គឺវាមានសារៈសំខាន់ណាស់ សម្រាប់ដំណើរការរបស់អង្គភាពនីមួយៗ និងបណ្តាលស្ថាប័ននានាប៉ុន្តែវិសាលភាពរបស់សវនកម្ម វាមានភាពធំធេងណាស់ ដូចនេះទើបខ្ញុំបាទលើកយកតែចំណុចសំខាន់តែមួយផ្នែកប៉ុណ្ណោះដើម្បីយកមកសិក្សាស្រាវជ្រាវ ដែលទាក់ទង និងខ្លឹមសារទាក់ទងនឹងប្រធានបទ « **ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២២ របស់ធនាគារ វីង (ខេមបូឌា) ម.ក នៅទីស្នាក់ការកណ្តាល** » ។ ការសិក្សាស្រាវជ្រាវទៅលើប្រធានបទទាក់ទងនឹងការធ្វើសវនកម្មនេះគ្រាន់តែជាគំនិតស្ទួចស្ទើង ហើយវាពិតជាមិនគ្រប់គ្រាន់ទាំងស្រុង អំពីការធ្វើសវនកម្មនោះទេគ្រាន់តែជាឯកសារជំនួស សម្រាប់ផ្តល់ការវិភាគទៅលើកិច្ចការមួយចំនួនតែប៉ុណ្ណោះ ប៉ុន្តែខ្ញុំបាទសង្ឃឹមថាវាជាការចូលរួមចំណែកមួយក្នុងការចូលរួមសង្គមជាតិ និងបានបន្សល់ទុកជាឯកសារដែលចងក្រងឡើងនេះសម្រាប់និស្សិតជំនាន់ក្រោយៗស្វែងយល់បន្ថែម។ យ៉ាងណាមិញក្នុងការស្រាវជ្រាវនេះនៅពុំទាន់មានន័យពេញលេញគ្រប់គ្រាន់ទេ អាស្រ័យហេតុនេះខ្ញុំបាទសូមអាធ្យាស្រ័យ និងសូមអភ័យទោសពីសំណាក់មិត្តអ្នកអានទាំងឡាយ និងសូមទទួលនូវរាល់ការរិះគន់ពីអ្នកអាន និងក្រុមអ្នកស្រាវជ្រាវទាំងអស់ដើម្បីជាការកែលម្អស្ថាបនា ដើម្បីឱ្យកាន់តែមានភាពរីកចម្រើនប្រសើរឡើង និងសុំទទួលនូវរាល់កំហុសឆ្គងដោយអចេតនាទាំងឡាយដែលមានក្នុងពាក្យពេចន៍ និងអក្ខរាវិរុទ្ធក្នុងឯកសារស្រាវជ្រាវរបស់ខ្ញុំ។

ជាទីបញ្ចប់ខ្ញុំបាទ សូមមេត្តាខន្តីអភ័យទោសពីសំណាក់សាស្ត្រាចារ្យ រាមច្បង និងមិត្តអ្នកអាន នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយខ្ញុំបាទរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្មនៃវិទ្យាស្ថាន វ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា** នាយកវិទ្យាស្ថាន វ៉ាន់ដា ក្នុងការផ្តល់អាហារូបករណ៍ ១០០ភាគរយ ដល់រូបខ្ញុំបាទ បានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញសវនកម្ម នៅវិទ្យាស្ថាន វ៉ាន់ដា។

លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្តល់នូវការលើកទឹកចិត្ត អនុគ្រោះដល់ខ្ញុំបាទរហូត ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត ភង ឱម** និងសាស្ត្រាចារ្យ **បេក្ខបណ្ឌិត យ៉ាក ឧត្តម** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់ខ្ញុំបាទឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ខ្ញុំបាទ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្តីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺៈ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ខ្ញុំបាទឈ្មោះ **លន់ សុខថា** សូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថារបាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយសារណាឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ថ្ងៃ.................ខែ................ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ភ្នំពេញ ថ្ងៃទី..........ខែ...........ឆ្នាំ២០....

**ហត្ថលេខា**



**លន់ សុខថា**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនការអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុឌីជីថលបានបង្ហាញថាប្រទេសដែលមានប្រព័ន្ធហិរញ្ញវត្ថុអភិវឌ្ឍន៍លូតលាស់ក្នុងអត្រាលឿនជាងមុន ដោយមានការបែងចែកយ៉ាងមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ការប្រុងប្រយ័ត្ននៃហិរញ្ញវត្ថុ ដែលរក្សាបាននូវការគ្រប់គ្រងហានិភ័យនៅក្នុងបរិយាកាសសេដ្ឋកិច្ចទាំងអស់។

បច្ចុប្បន្នវិស័យធនាគារ នៅប្រទេសកម្ពុជាកំពុងបន្តការអភិវឌ្ឍន៍យ៉ាងរឹងមាំ ជាមួយកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។ ជាមួយការរីកចម្រើននិងកំណើនជឿទុកចិត្តរបស់ប្រជាជនកម្ពុជាមកលើប្រព័ន្ធធនាគារ កត្តាចម្បងរបស់ធនាគារ បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយបានឆ្លងកាត់ការធ្វើសវនកម្មជាមុន ដើម្បីឱ្យអ្នកប្រើប្រាស់ខាងក្រៅយកទៅអាន ធ្វើការវិភាគ និងសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។ ទាំងនេះបានជំរុញធ្វើឱ្យវិស័យធនាគារនៅកម្ពុជា បានបន្តការអភិវឌ្ឍន៍ដោយភាពរឹងមាំក្នុងការពង្រឹង ដើម្បីលើកកម្ពស់ប្រសិទ្ធភាព គុណភាពនៃប្រតិបត្តិការបង្កើនបរិមាណ និងគុណភាពដើមទុន រួមទាំងសមត្ថភាពធនធានមនុស្ស ដោយគុណវុឌ្ឍិ បានយ៉ាងឆាប់រហ័ស។

ចំពោះរបាយការណ៍សំខាន់ៗនៃការស្រាវជ្រាវ ខ្ញុំបាទបានធ្វើការប្រមូលទិន្នន័យមួយចំនួនដែលទាក់ទងជាមួយនិង ធនាគារ វីង (ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល ដែលបង្ហាញអំពីប្រតិបត្តិការ ទស្សនៈវិស័យ បេសកកម្ម រចនាសម្ព័ន្ធ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ របស់ធនាគារ វីង (ខេមបូឌា) ម.ក នៅទីស្នាក់ការកណ្តាលផ្ទាល់។ ការសិក្សាពីដំណើរការ គ្រប់គ្រងប្រព័ន្ធសវនកម្មផ្ទៃក្នុង ការរៀបចំផែនការនឹងនីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុង និងការប្រមូលឯកសារដែលមានស្រាប់ចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយស្របតាមវិធីសាស្ត្រ Financial Accounting និងការធ្វើសវនកម្មផ្ទៃក្នុងស្របតាមវិធីសាស្ត្រ Financial Audit សំដៅការទទួលបានព័ត៌មាន ការវិភាគ និងការសន្និដ្ឋានក្នុងអំឡុងពេលត្រួតពិនិត្យ ឬអធិការកិច្ច សម្រាប់គ្រាំទ្រដល់លទ្ធផលរកឃើញ និងការផ្តល់អនុសាសន៍នានា។

ឆ្លងកាតរយៈនៃការស្រាវជ្រាវ ដែលទាក់ទងនឹងការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ វីង(ខេមបូឌា)ម.ក ទីស្នាក់ការកណ្តាល រួចមក ខ្ញុំបាទអាចសរុបសង្ខេបបានថា ធនាគារអាចគ្រប់គ្រងហិរញ្ញវត្ថុបានល្អក្នុងការផ្តល់ទំនុបចិត្តខ្ពស់សម្រាប់សាធារណជន គឺមានការដាក់របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មជាមុនស្របតាមស្តង់ដារដែលរាជរដ្ឋាភិបាលបានកំណត់ជាមុនក្នុងការចេញផ្សាយដើម្បីបញ្ជាក់ភស្តុតាងជាក់ស្តែងឆ្ពោះទៅរកភាពរីកចម្រើន។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
សេចក្តីថ្លែងអំណរគុណ ........ ii
អំណះអំណាង ........ iii
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ iv
**ជំពូកទី១: សេចក្តីផ្តើម**
១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤
**ជំពូកទី២: រំលឹកទ្រឹស្តី**
២.១ លក្ខណៈទូទៅនៃការធ្វើសវនកម្ម ........ ៥
២.១.១ និយមន័យនៃសវនកម្ម ........ ៥
២.១.២ ប្រវត្តិនៃសវនកម្ម ........ ៦
២.១.៣ ប្រភេទផ្សេងគ្នានៃសវនកម្ម ........ ៧
២.២ សមាសធាតុនៃរបាយការណ៍ហិរញ្ញវត្ថុ ........ ១៤
២.២.១ និយមន័យនៃរបាយការណ៍ហិរញ្ញវត្ថុ ........ ១៤
២.២.២ ប្រវត្តិនៃរបាយការណ៍ហិរញ្ញវត្ថុ ........ ១៨
២.២.៣ តួនាទីនៃរបាយការណ៍ហិរញ្ញវត្ថុ ........ ១៩
២.៣ ផែនការនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ........ ២០
២.៣.១ និយមន័យនៃផែនការ ........ ២០
២.៣.២ ប្រវត្តិនៃការរៀបចំផែនការ ........ ២០
២.៣.៣ វិធីសាស្ត្រក្នុងការធ្វើផែនការ ........ ២១
២.៤ ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ........ ២៤
២.៤.១ និយមន័យនៃធនាគារ ........ ២៤
២.៤.២ ប្រវត្តិនៃធនាគារ ........ ២៤
២.៤.៣ តួនាទីរបស់ធនាគារ ........ ២៥

## ជំពូកទី៣: លទ្ធផលនៃការស្រាវជ្រាវ


៣.១ ស្ថានភាពទូទៅរបស់ធនាគារ វីង (ខេមបូឌា)ម.ក ........................................ ២៦
៣.១.១ ប្រវត្តិរបស់ធនាគារ វីង (ខេមបូឌា)ម.ក ........................................ ២៦
៣.១.២ បេសកកម្ម និងទស្សនវិស័យ ........................................ ២៨
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង ........................................ ២៨
៣.២ សមាសធាតុរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវីង ........................................ ២៩
៣.២.១ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........................................ ៣០
៣.២.២ របាយការណ៍លទ្ធផលពេញលេញ ........................................ ៣១
៣.២.៣ របាយការណ៍បម្រែបម្រួលមូលធន ........................................ ៣២
៣.២.៤ របាយការណ៍លំហូរសាច់ប្រាក់ ........................................ ៣៣
៣.៣ ផែនការនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវីង ........................................ ៣៤
៣.២.១ ផែនការនៃការធ្វើសវនកម្ម ........................................ ៣៤
៣.២.២ នីតិវិធីនៃការធ្វើសវនកម្ម ........................................ ៣៤
៤.៤ ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ........................................ ៣៧


## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង ........................................ ៣៩
៤.២ ការវិភាគលើចំណុចខ្សោយ ........................................ ៤០


## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ........................................ ៤១
៥.២ ការផ្តល់អនុសាសន៍ ........................................ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

កម្ពុជាបានបោះជំហានរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងបានរៀបចំខ្លួនរួចជាស្រេចដើម្បីចូលរួមក្នុងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អាស៊ីអាគ្នេយ៍ និងបំពេញតួនាទីរបស់ខ្លួននៅក្នុងឆាកអន្តរជាតិ។ កម្ពុជាបានបើកទំព័រប្រវត្តិសាស្ត្ររបស់ខ្លួន ដោយកប់ចោលយ៉ាងជ្រៅនូវយុគដ៏ខ្មៅងងឹត និងសោកនាដកម្មដ៏សែនឈឺចាប់ពីអតីតកាល និងបានបោះជំហានឆ្ពោះនៅលើវិថីមួយប្រកបដោយក្តីសង្ឃឹម។ សមិទ្ធផលដ៏ត្រចះត្រចង់នេះ អាចសម្រេចបានតាមរយៈការប្តេជ្ញាចិត្តយ៉ាងមុតមាំ និងភាពសះស្បើយពីរបួសចាស់នៃសោកនាដកម្មប្រល័យពូជសាសន៍ ដែលបច្ចុប្បន្ននេះប្រជាជនកម្ពុជាកំពុងតែរីករាយនឹងសន្តិភាព និងស្ថិរភាពនយោបាយ។ លទ្ធិប្រជាធិបតេយ្យ បានចាក់ឫសយ៉ាងមាំក្នុងសង្គមកម្ពុជា សណ្តាប់ធ្នាប់សាធារណៈ និងនីតិរដ្ឋមានការរីកចម្រើនជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃធ្វើឱ្យមានលំហូរនៃវិនិយោគទុនបរទេសចូលមកបណ្តាក់ទុនរកស៊ីយ៉ាងផុសផុលលើគ្រប់វិស័យ ជាអាទិ៍ វិស័យទេសចរណ៍ សណ្ឋាគារ កន្លែងកំសាន្តសហគ្រាសពាណិជ្ជកម្មខ្នាតតូច មធ្យម និងធំ និងជាពិសេសនោះគឺ វិស័យធនាគារ ដែលគេសង្កេតឃើញមានការរីកចម្រើនដល់ខឿនសេដ្ឋកិច្ចរបស់កម្ពុជា។ ដោយការរីកចម្រើនខ្លាំងផ្នែកវិស័យធនាគារដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ដាក់បង្កើតបរិយាកាសល្អដល់អ្នកវិនិយោគលើវិស័យនេះ ដូចជាការបង្កើតឱ្យមានច្បាប់ និងបទដ្ឋានគតិយុត្តគ្រប់គ្រាន់សម្រាប់បម្រើដល់វិស័យធនាគារ ដែលរួមមាន ច្បាប់ស្តីពីគណនេយ្យសហគ្រាស វិជ្ជាជីវៈ គណនេយ្យនិងសវនកម្ម ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកទទួលខុសត្រូវហើយក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបានបង្កើតឡើងដើម្បីកំណត់ស្តង់ដារគណនេយ្យនិងសវនកម្ម។ ស្តង់ដារគណនេយ្យនិងសវនកម្មអន្តរជាតិកំពុងត្រូវបានអនុវត្តន៍ ដោយសម្រេចបាននូវវឌ្ឍន៍ភាពជាច្រើនក្នុងការបង្កើតគណនេយ្យករ និងសវនករដែលជាមួយគ្នានេះ វិទ្យាស្ថានគណនេយ្យករជំនាញ និងត្រូវបានត្រួតពិនិត្យដោយអ្នកគ្រប់គ្រង ហើយអះអាងថា របាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានរៀបចំឡើងស្របទៅតាម គោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ GAAP (General Accepted Accounting Principle) ឬ ក្រុមប្រឹក្សាកំណត់ស្តង់ដារគណនេយ្យអន្តរជាតិ IFRS/IAS (International Accounting Standard)។

បច្ចុប្បន្នជាសម័យសេរីភាវូបនីយកម្មនិងបច្ចេកវិទ្យាឌីជីថលការប្រកួតប្រជែងវានាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ចដ៏សំខាន់នៅក្នុងបរិបទទ្រទ្រង់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងធនាគារ ព្រមទាំងជួយកាត់បន្ថយភាពក្រីក្រ នេះបើយោងទៅតាមការស្រាវជ្រាវ និងបទពិសោធន៍កន្លងមកបានបង្ហាញដូចនេះ។ ទន្ទឹមនឹងនេះសេរីភាវូបនីយកម្មក៏នាំមកនូវហានិភ័យមួយចំនួន ដែលចាំបាច់ត្រូវតែធ្វើការដោះស្រាយឱ្យបានសមស្រប។ សំខាន់ជាងនេះទៅទៀតសេរីភាវូយកម្មនេះ កើតឡើងដោយគ្មានលំដាប់លំដោយសមស្រប និងការអភិវឌ្ឍក្របខណ្ឌច្បាប់ និងបទបញ្ញត្តិ ដើម្បីកាត់បន្ថយហានិភ័យ។ គណៈកម្មាធិការបាសែល (Basell Committees) បានចែងជាច្បាប់ សម្រាប់ត្រួតពិនិត្យធនាគារដែលជាតួនាទីរបស់ធនាគារកណ្តាល ហើយការត្រួតពិនិត្យធនាគារក៏ដើរតាមក្បួនខ្នាត និងបទដ្ឋានបាសែល (Basel) ដែលមានចែងពីគោលការណ៍ស្នូលទាំង ២៥ ក្នុងការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាព។

ដូចនេះ ចំពោះអាជីវកម្មធនាគារត្រូវមានការត្រួតពិនិត្យបន្ថែមទៀតពី ធនាគារជាតិនៃកម្ពុជា ដែលជាអាណាព្យាបាលប្រព័ន្ធធនាគារ ក្នុងគោលបំណងឱ្យប្រព័ន្ធធនាគារមួយដែលមានសុវត្ថិភាព សមត្ថភាព និងប្រសិទ្ធភាពទាំងនេះជាកត្តាដ៏មានសារៈសំខាន់ក្នុងការគ្រាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ។ ធនាគារដែលគ្មានសុវត្ថិភាពអាចនាំឱ្យមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ីកាលឆ្នាំ១៩៩៧-១៩៩៨ ជាដើម។ ទន្ទឹមនឹងនេះដែរ ធនាគារជាតិនៃកម្ពុជាក៏ទាមទារឱ្យធនាគារពាណិជ្ជទាំងអស់ត្រូវតែបង្កើតនូវ សវនកម្មផ្ទៃក្នុង និងចាំបាច់ត្រូវមានសេវាសវនកម្មផ្ទៃក្រៅ ដែលមានលក្ខណៈឯករាជ្យដើម្បីធ្វើការអះអាងលើរបាយការណ៍ហិរញ្ញវត្ថុដែលទទួលស្គាល់ដោយសាធារណៈជន CPA (Certified Public Accountants)។

ដោយមើលឃើញពីសារៈសំខាន់បែបនេះទើបខ្ញុំបាទ ជ្រើសរើសប្រធានបទ "ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២២ របស់ធនាគារ វីង (ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល" យកមកធ្វើការស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថា ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ គឺដើរតួនាទីយ៉ាងសំខាន់សម្រាប់ស្ថាប័នរដ្ឋ ប្រព័ន្ធធនាគារ និងក្រុមហ៊ុននីមួយៗដែលមានរចនាសម្ព័ន្ធជាក់លាក់ រួមមានៈក្រុមប្រឹក្សាភិបាល (Board of Director) គណៈគ្រប់គ្រង(Management) ហើយនិងបុគ្គលិក(Staff) ដ៏ទៃទៀត។ អ្នកទាំងអស់នេះរួមដៃគ្នា ធ្វើយ៉ាងណាឱ្យធនាគារអាចដំណើរការបានដោយផ្តល់នូវការអះអាងដ៏សមហេតុផល។ ដូចនេះ ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទាមទារឱ្យមានការយល់ដឹងច្បាស់លាស់ទៅលើប្រព័ន្ធគណនេយ្យ និងប្រព័ន្ធសវនកម្ម ដើម្បីយកមកធ្វើផែនការសវនកម្មនិងអភិវឌ្ឍន៍វិធីសាស្ត្រសវនកម្មឱ្យមានប្រសិទ្ធភាព និងដាក់ចេញនូវនីតិវិធីសវនកម្ម ធ្វើយ៉ាងណាឱ្យមានការជឿជាក់ថា ហានិភ័យទាំងនោះត្រូវបានកាត់បន្ថយឱ្យនៅក្នុងកម្រិតទាបបំផុត ដែលយើងអាចគ្រប់គ្រង និងទទួលយកបាន។ ម្យ៉ាងវិញទៀត ដើម្បីឱ្យការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុអាចប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលផ្លែផ្ការ សវនករគួរតែយល់ដឹងនូវបណ្តាលចំនុចមួយចំនួនឱ្យបានច្បាស់លាស់ថា៖

១. តើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ វីង មានសមាសភាពអ្វីខ្លះ?

២. តើផែនការនៃការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ វីង(ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល ប្រចាំឆ្នាំ២០២២ មានលក្ខណៈដូចម្តេច?

៣. តើការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ធនាគារ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទាក់ទងនឹងការធ្វើសវនកម្មនេះ ក្នុងគោលបំណងសិក្សាស្វែងយល់ទៅលើដំណើរការនៃការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២២ របស់ធនាគារ វីង (ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល។ យើងនឹងធ្វើការសិក្សាប្រៀបធៀបរវាងទ្រឹស្តី ដែលបានសិក្សាកន្លងមកជាមួយនឹងការអនុវត្តន៍ជាក់ស្តែង រួចធ្វើការវាយតម្លៃបន្ថែមដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រតិបត្តិការរបស់ធនាគារវីង។ ម្យ៉ាងទៀត ដើម្បីឆ្លុះបញ្ចាំងនូវដំណើរការ និងប្រតិបត្តិការលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារទាក់ទងនឹងការធ្វើសវនកម្មផ្ទៃក្នុងលើហិរញ្ញវត្ថុដែលយើងនិងសិក្សាក្នុងគោលបំណងចម្បងសំខាន់ៗដូចខាងក្រោម៖

- ស្ថានភាពទូទៅរបស់ធនាគារ វីង (ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល
- ដំណើរការនៃការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ
- ផលប្រយោជន៍នៃការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ
- ការវិភាគរកចំណុចខ្លាំង និងចំណុចខ្សោយ
- ការសន្និដ្ឋាន និងអនុសាសន៍។

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ដែនកំណត់នៃការស្រាវជ្រាវ

ដោយរយៈពេលមានកំណត់ ចំពោះការសិក្សាស្រាវជ្រាវ ឯកសារមួយចំនួនរបស់ធនាគារមិនបានទូលំ-ទូលាយ ហេតុដូចនេះធ្វើឱ្យខ្ញុំបាទមានការលំបាកក្នុងការប្រមូលទិន្នន័យឱ្យបានគ្រប់ជ្រុងជ្រោយ។ ដូចនេះហើយទើបខ្ញុំបាទផ្តោតទៅលើចំណុចសំខាន់ ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារវីង(ខេមបូឌា)ម.ក ទីស្នាក់ការកណ្តាល ក្នុងការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ការសិក្សាស្រាវជ្រាវបានតាមរយៈ https://www.wingbank.com.kh/km/about-wing/annual-report/ មកធ្វើការសិក្សាប៉ុណ្ណោះ។

### ១.៤.២ វិសាលភាពនៃការសិក្សាស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវនេះ គឺផ្តោតយកចិត្តទុកដាក់ទៅលើប្រធានបទ៖ ការធ្វើសវនកម្មផ្ទៃក្នុងទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ វីង (ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល រាជធានីភ្នំពេញ ក្នុងការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ សម្រាប់បញ្ហាផ្សេងៗដែលមិនទាក់ទងនឹងប្រធានបទ ខ្ញុំបាទមិនបានលើកយកមកបកស្រាយក្នុងការសរសេរលម្អិតនោះទេ។ ដោយការសរសេរក្នុងរបាយការណ៍នេះ គឺការប្រមូលទិន្នន័យពីស្ថាប័នខាងលើផ្តល់តាមរយៈនៃការស្រាវជ្រាវ។ ទន្ទឹមនឹងនោះ ខ្ញុំបាទសង្ឃឹមដោយភាពជឿ-ជាក់ថា ក្រោយពីបានបញ្ចប់របាយការណ៍ស្រាវជ្រាវនេះ នឹងទទួលបាននូវអ្វីដែលថ្មី និងបទពិសោធន៍បន្ថែមក្នុងការសរសេរនូវរបាយការណ៍ដោយផ្សារភ្ជាប់ជាមួយទ្រឹស្តី និងការអនុវត្តន៍ដោយឆន្ទៈចំណេះដឹង។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបាន ត្រូវបានលើកយកនូវវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ និងព័ត៌មានដែលជាប់ទាក់ទងនិងប្រធានបទមកធ្វើការបកស្រាយ និងបានចងក្រងសៀវភៅនេះឡើង។ ដោយធ្វើការប្រមូលឯកសារបន្ទាប់បន្សំនិងដោយផ្ទាល់ រួមមានដូចជា ការផ្តល់ការណែនាំនិងមតិយោបល់សាស្ត្រាចារ្យស្រាវជ្រាវពីបណ្ណាល័យដែលមានទំនាក់ទំនងនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណែតផងដែរ។

### ១.៥.១ វិធីសាស្ត្រប្រមូលទិន្នន័យបន្ទាប់បន្សំ

ការប្រមូលឯកសារដែលមានស្រាប់ គឺជាការប្រមូលទិន្នន័យបានតាមរយៈបណ្ណាល័យ ដែលយើងពឹងអាស្រ័យលើការសិក្សាទ្រឹស្តី ការអានសារណា ដែលនិស្សិតរៀមច្បងជំនាន់មុនៗដែលបានធ្វើកន្លងមក។

### ១.៥.១ វិធីសាស្ត្រប្រមូលទិន្នន័យ ដោយផ្ទាល់

- ឯកសារទទួលបានពីធនាគារវីង(ខេមបូឌា)ម.ក ភ្នំពេញជាសៀវភៅរបាយការណ៍ប្រចាំឆ្នាំ ២០២២ ដែលបានដាក់តាំងបង្ហាញនិងបោះពុម្ពផ្សព្វផ្សាយ

- ស្វែងរកឯកសារ ដែលជាប់ទាក់ទងនឹងប្រធានបទនៅបណ្ណាល័យ
- តាមរយៈប្រព័ន្ធអ៊ីនធើណែត
- តាមរយៈការណែនាំរបស់សាស្ត្រចារ្យដឹកនាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវបានផ្តល់នូវសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន រួមមាន៖

- ពង្រឹងមូលដ្ឋានចំណេះដឹងកាន់តែស៊ីជម្រៅ និងស្វែងយល់បន្ថែមចំពោះទស្សនៈផ្សេងៗ
- ទទួលបានបទពិសោធន៍ផ្ទាល់ខ្លួនជាមួយប្រធានបទ និងឱកាសថ្មីសម្រាប់ការរៀនសូត្រ
- អាចជួយក្នុងការដោះស្រាយបញ្ហាប្រឈម បង្កើតផែនការ និងយុទ្ធសាស្ត្រដើម្បីទប់ស្កាត់
- ជួយកំណត់អត្តសញ្ញាណប្រធានបទ ក្នុងការជ្រើសរើសជាគម្រោង និងគោលដៅ
- ស្វែងយល់ក្នុងការរៀបចំការងារជាប្រព័ន្ធនៃការទទួលភារកិច្ចរបស់បុគ្គលិកនៅក្នុងអង្គភាព
- រក្សាទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ នូវចំណេះដឹង និងការអនុវត្តន៍ និងដល់អ្នកសិក្សាទូទៅដែលមានបំណងចង់យល់ដឹងពីដំណើរការនៃការធ្វើសវនកម្មផ្ទៃក្នុងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគាររីង (ខេមបូឌា)ម.ក ហើយក៏ជាការវាស់វែងសមត្ថភាពរបស់ខ្លួនក្រោយបញ្ចប់ការសិក្សា។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវចែកចេញជា ៥ ជំពូកដូចខាងក្រោមៈ

ជំពូកទី១ ៖ សេចក្តីផ្តើមៈ នៅជំពូកនេះត្រូវបានបង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។

ជំពូកទី២ ៖ រំលឹកទ្រឹស្តីៈ និយាយអំពីទ្រឹស្តី និយមន័យសវនកម្ម និយមន័យធនាគារ និយមន័យផែនការ ប្រវត្តិរបាយការណ៍ហិរញ្ញវត្ថុ និងនិយមន័យរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ និងទស្សនៈទាននៃប្រធានបទ និងបទពិសោធន៍ផ្សេងៗទៀត។

ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវៈ លើកឡើងពីស្ថានភាពទូទៅរបស់អង្គភាពដូចជា ប្រវត្តិរបស់អង្គភាព បេសកកម្ម ទស្សនវិស័យ គោលនយោបាយ រចនាសម្ព័ន្ធចាត់តាំង (តួនាទីនិងភារកិច្ច) និងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មផ្ទៃក្នុងរួច របស់ធនាគារ រីង (ខេមបូឌា) ម.ក នៅទីស្នាក់ការកណ្តាលសម្រាប់ការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ។

ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយៈ ការលើកឡើងពីការអនុវត្តន៍ជាក់ស្តែងក្នុងគោលបំណង វិភាគឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីធ្វើការកែលម្អឡើងវិញ។

ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍ៈ លើកអំពីការធ្វើការសិន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់ជាយោបល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អឡើងវិញ។

# ជំពូកទី២
# ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

## ២.១ លក្ខណៈទូទៅនៃការធ្វើសវនកម្ម

### ២.១.១ និយមន័យនៃសវនកម្ម

សវនកម្ម គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតពីរបៀបតាមដាន ឆែកឆេរ រុករក ស្ទាក់ចាប់ ប្រមូលភស្តុតាង រួចធ្វើការវាយតម្លៃ ដោយមានគោលបំណងដើម្បីកំណត់វិសាលភាពដែលមានលក្ខណៈវិនិច្ឆ័យសវនកម្ម (គោលនយោបាយ និងនីតិវិធី ឬតម្រូវការ) ត្រូវបានបំពេញ[1]។

សវនកម្ម គឺជាគោលដៅដល់ការស្រាវជ្រាវ សើបអង្កេត ពិនិត្យផ្ទៀងផ្ទាត់ទៅលើដំណើរការប្រព័ន្ធគុណភាព ដើម្បីឆ្លើយតបនឹងតម្រូវការស្តង់ដារណាមួយដែលគេចង់បាន។ ក្រៅពីនេះ សវនកម្ម ក៏អាចយកទៅប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃបានដូចជា សវនកម្មលើសកម្មភាពការងារ សវនកម្មលើផលិតផល សវនកម្មអំពីហានិភ័យរបស់ក្រុមហ៊ុន ឬស្ថាប័ន[2]។

សវនកម្ម គឺជាការពិនិត្យ ឬត្រួតពិនិត្យសៀវភៅគណនីផ្សេងៗ ដោយសវនករ អមដោយការត្រួតពិនិត្យសារពើភ័ណ្ឌ ដើម្បីប្រាកដថាគ្រប់នាយកដ្ឋានទាំងអស់កំពុងអនុវត្តន៍តាមប្រព័ន្ធប្រតិបត្តិការ ដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬស្ថាប័នណាមួយ។

តាមពិតទៅ សវនកម្ម អាចធ្វើឡើងបានគ្រប់ក្រុមហ៊ុន និងស្ថាប័នទាំងអស់ ប៉ុន្តែជាទូទៅ នៅស្ថាប័ន ឬក្រុមហ៊ុន នៅពេលដែលឮពាក្យសវនកម្ម (Audit) គេតែងតែគិតដល់ការស្រាវជ្រាវ សើបអង្កេត អំពីហិរញ្ញវត្ថុក្រុមហ៊ុន។ ប្រសិននិយាយឱ្យងាយយល់ វាជាការផ្ទៀងផ្ទាត់ ពិនិត្យពីភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬស្ថាប័នណាមួយដែលធ្វើឡើងដោយសវនករ។ សវនកម្មមានច្រើនប្រភេទ ក្រៅពីសវនកម្មហិរញ្ញវត្ថុ (Financial Audit) ក្រុមហ៊ុន សវនកម្មក៏មានប្រភេទផ្សេងៗដូចជា សវនកម្មពន្ធដា (Tax Audit) ជាដើម។ ដូចគ្នានេះផងដែរ ការធ្វើសវនកម្មគឺជាភាពជឿជាក់ ជាមួយប្រព័ន្ធគ្រប់គ្រងសវនកម្មផ្ទៃក្នុង ចំពោះអាជីវកម្មរបស់លោកអ្នកអាចបង្កើតរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ និងអាចទុកចិត្តបានតាមរយៈអ្នកអាចយល់ដឹងអំពីផ្នែក ឬបន្ទាត់ផលិតផលដែលកំពុងដំណើរការល្អបំផុត និងរបៀបបែងចែកធនធានបានត្រឹមត្រូវ។ លើសពីនេះ ការធ្វើសវនកម្មជាទៀតទាត់នឹងធ្វើឱ្យម្ចាស់ភាគហ៊ុនរបស់អ្នកជឿទុកចិត្តថាគណនេយ្យរបស់អ្នកគឺពិតជាយុត្តិធម៌ ហើយមានសុវត្ថិភាពក្នុងការវិនិយោគក្នុងអាជីវកម្មរបស់អ្នក។

បច្ចុប្បន្ន សវនកម្មត្រូវបានគេប្រើជាទូទៅ និងមាននិយមន័យ ការត្រួតពិនិត្យដោយលម្អិត និងពិនិត្យឡើងវិញនូវប្រព័ន្ធដំណើរការ និងទិន្នន័យ។

ដូច្នេះ សវនកម្មត្រូវបានកំណត់ថា គឺជាដំណើរការនៃការតាមដាន និងឆែកឆេរ ប្រមូលនូវភស្តុតាងសវនកម្ម ទៅលើការជានាអះអាងរបស់អ្នកគ្រប់គ្រង និងលក្ខណៈវិនិច្ឆ័យដែលបង្កើតឡើង ហើយចុងក្រោយផ្សព្វផ្សាយនូវលទ្ធផលនេះ ទៅកាន់អ្នកប្រើប្រាស់ដែលពាក់ព័ន្ធ[3]។

---

[1] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្ទៃកទីI ទំព័រទី៣-៥,ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

[2] https://khemsarith.wordpress.com/(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

[3] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

### ២.១.២ ប្រវត្តិនៃសវនកម្ម

សវនកម្ម ត្រូវបានមកពីពាក្យឡាតាំង AUDITING មានន័យថាដើម្បីស្តាប់ពីព្រោះនៅសម័យបុរាណ សវនករបានស្តាប់របាយការណ៍ផ្ទាល់មាត់របស់មន្ត្រីទទួលខុសត្រូវចំពោះម្ចាស់ ឬអ្នកដែលមានអំណាច ហើយបានបញ្ជាក់ពីភាពត្រឹមត្រូវនៃរបាយការណ៍។ ប៉ុន្មានឆ្នាំចុងក្រោយនេះសវនករបានវិវត្តន៍ដើម្បីផ្ទៀងផ្ទាត់កំណត់ត្រាដែលបានសរសេរ។ ការអនុវត្តន៍សវនករមុនៗ ទោះបីមិនសូវមានឯកសារច្បាស់លាស់អំពីសវនកម្មក៏ដោយ សវនកម្មត្រូវបានគេរកឃើញថាមាននៅក្នុងវប្បធម៌ចិន អេហ្ស៊ីបបុរាណ និងក្រិច ក្នុងទម្រង់នៃសកម្មភាពត្រួតពិនិត្យបុរាណ។ សកម្មភាពត្រួតពិនិត្យ ដែលត្រូវបានរកឃើញនៅក្នុងប្រទេសក្រិចបុរាណហាក់ដូចជាប្រហាក់ប្រហែលទៅនិងសវនកម្មបច្ចុប្បន្ន។ នៅក្នុងឆ្នាំ១៤៩៤ (Luca Pacioli) បានបោះពុម្ពសៀវភៅស្តីពីប្រព័ន្ធគណនេយ្យទ្វេដងនៃគណនេយ្យដែលប្រើប្រាស់ដោយពាណិជ្ជករនៅទីក្រុង Venice ប្រទេសអ៊ីតាលី។ នេះជាសៀវភៅដំបូងស្តីពីគណនេយ្យនិងសវនកម្មទំនើបបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៨៤៤ នៅពេលដែលរដ្ឋមន្ត្រីសភាអង់គ្លេស បានអនុម័តច្បាប់រួមគ្នារបស់ក្រុមហ៊ុនភាគហ៊ុន សម្រាប់សកម្មភាពដំបូងដែលនាយកបានតម្រូវឱ្យរាយការណ៍ទៅម្ចាស់ភាគហ៊ុនតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើរបាយការណ៍តុល្យការ។ នៅក្នុងទសវត្សឆ្នាំ ១៨៤៤ សវនករមិនចាំបាច់ជាគណនេយ្យករ ឬសវនករឯករាជ្យទេ ប៉ុន្តែនៅក្នុងឆ្នាំ ១៩០០ ច្បាប់ក្រុមហ៊ុនថ្មីៗត្រូវបានអនុម័តដែលតម្រូវឱ្យសវនករឯករាជ្យ[4]។

សមាគមន៍គណនេយ្យករសាធារណៈដំបូងបង្អស់ គឺសមាគមន៍គណនេយ្យករនៅ អេឌីនបឺក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៥៤។ សមាគមន៍គណនេយ្យករសាធារណៈអាមេរិចកាំងត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៨៧ ដែលក្រោយមកក្លាយទៅជាវិទ្យាស្ថានគណនេយ្យករសាធារណៈ (AICPA) American Institute of Certified Public Accountants រហូតមកដល់ឆ្នាំ ១៩៣០ សវនកម្មត្រូវបានតម្រង់ទិសប្រតិបត្តិការនោះគឺវាផ្តោតលើនីតិវិធីដែលបានអនុវត្តន៍ដើម្បីដំណើរប្រតិបត្តការនីតិវិធីទាំងនេះភាគច្រើនពឹងផ្អែកលើភស្តុតាងផ្ទៃក្នុងការអនុវត្តន៍របស់សហរដ្ឋអាមេរិចបានវិវត្តន៍តាំងពីសតវត្សរ៍ទី ១៩ ឆ្ពោះដំណើរការនៃការប្រមូលភស្តុតាងដែលទាក់ទងនិងបំណុលឬអ្វីដែលមានការយល់ច្រឡំយ៉ាងទូលំទូលាយដែលបានរួមចំណែកដល់ការដួលរលំនៃផ្សារភាគហ៊ុននៅឆ្នាំ ១៩២៩ ។ សកម្មភាពមូលបត្ររបស់សហរដ្ឋអាមេរិចនៅក្នុងឆ្នាំ ១៩៣៣ ដល់១៩៣៤ បានបង្កើតគណៈកម្មាធិការមូលបត្រ (SEC) ដែលគ្រប់គ្រងលើការដោះដូរភាគហ៊ុនធំៗ នៅសហរដ្ឋអាមេរិច។ ច្បាប់ទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការធ្វើសវនកម្មជុំវិញពិភពលោក។ ក្រុមហ៊ុនដែលមានបំណងធ្វើពាណិជ្ជកម្មភាគហ៊ុននៅញូវយ៉ក ឬផ្សារភាគហ៊ុន អាមេរិចត្រូវបានតម្រូវឱ្យចេញរបាយការណ៍ប្រាក់ចំណូល ក៏ដូចជាតារាងតុល្យការ។ ដូចគ្នានេះផងដែរដោយសារបញ្ហាមុនៗជាមួយរបាយការណ៍ហិរញ្ញវត្ថុមិនត្រឹមត្រូវនៃទសវត្សរ៍ឆ្នាំ ១៩២០ ការសង្កត់ធ្ងន់បានប្តូរទៅជាភាពយុត្តិធម៌នៃការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងតួនាទីរបស់សវនករ គឺដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការបង្ហាញ។ ឆ្នាំ ១៩៦០ ដល់ឆ្នាំ១៩៩០ ភារកិច្ចរបស់សវនករក្នុងចំណោមអ្នកផ្សេងៗទៀតគឺត្រូវបានធានាថារបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ។ តួនាទីរបស់សវនករដែលទាក់ទងទៅនឹង ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុជាទូទៅនៅតែដដែលដូចកាលពីមុន។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ការផ្លាស់ប្តូរវិធីសាស្ត្រសវនកម្មត្រូវបានគេសង្កេតឃើញថាពីការផ្ទៀងផ្ទាត់ប្រតិបត្តិការនៅ

[4] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

ក្នុងសៀវភៅ "ទៅលើការពឹងផ្អែកលើប្រព័ន្ធព័ត៌មាន IT" ការផ្លាស់ប្តូរបែបនេះ គឺដោយសារការកើតឡើងនូវចំនួនប្រតិបត្តិការដែលបណ្តាលមកពីការបន្តកើនឡើងទំហំ និងភាពស្មុគស្មាញរបស់ក្រុមហ៊ុនដែលវាទំនងសម្រាប់សវនករដើរតួរក្នុងការផ្ទៀងផ្ទាត់ប្រតិបត្តិការ។ ជាលទ្ធផលសវនករនៅក្នុងរយៈពេលនេះបានដាក់ការពឹងផ្អែកខ្ពស់ទៅលើការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុននៅក្នុងនីតិវិធីសវនកម្មរបស់គេ។ និងនៅពេលដែលការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនមានប្រសិទ្ធភាព សវនករកាត់បន្ថយកម្រិតនៃការធ្វើតេស្តលម្អិត(Type of Test) ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ មានការកែទម្រង់មួយនៅក្នុងវិធីសាស្រ្តរបស់សវនករ ដែលការវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានគេរកឃើញថាជាដំណើរការដែលមានតម្លៃថ្លៃដូច្នេះផ្នែកនេះគឺជាការអភិវឌ្ឍន៍កំឡុងពេលពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ ទៅលើការធ្វើសវនកម្មដោយផ្អែកលើហានិភ័យ។ ការធ្វើសវនកម្មផ្អែកលើហានិភ័យ គឺជាវិធីសាស្រ្តសវនកម្មដែលសវនករនឹងផ្តោតទៅផ្នែកឬតំបន់ទាំងនោះដែលទំនងជាមានកំហុស។ នៅដើមទសវត្សរ៍ឆ្នាំ ២០០០ មានរឿងអាស្រូវគណនេយ្យផ្សេងៗដូចជា WorldCom, Tyco ជាដើម។ ដើម្បីឆ្លើយតបទៅនឹងច្បាប់ Enron រដូវការស្លឹកឈើជ្រុះ Sarbanes-Oxley ក្នុងឆ្នាំ ២០០២ ត្រូវបានអនុម័តដែលនាំមកនូវបទប្បញ្ញត្តិគណនេយ្យជាច្រើនសម្រាប់គ្រប់គ្រងសវនករ។ ទោះបីគោលការណ៍ នីតិវិធី និងការផ្លាស់ប្តូរសំខាន់ៗត្រូវបានធ្វើឡើងហើយចុះការអនុវត្តន៍លើការធ្វើសវនកម្មដែលជាលទ្ធផលនៃការកែទម្រង់យ៉ាងទូលំទូលាយនៅក្នុងប្រទេសផ្សេងៗផងដែរ។

**២.១.៣ ប្រភេទផ្សេងគ្នានៃសវនកម្ម**

**ក. សវនកម្មផ្ទៃក្នុង** (Internal Audit) គឺជាមុខវិទ្យាមួយបែបវិទ្យាសាស្រ្តដែលសិក្សាលម្អិតពីរបៀបតាមដានឆែកឆេរ ប្រមូលភស្តុតាង រួចវាយតម្លៃថា តើអ្នកគ្រប់គ្រងមានបានអនុវត្តន៍តាមគោលនយោបាយនិងនីតិវិធីផ្ទៃក្នុង ដើម្បីទទួលបានគោលដៅទាំងបីយ៉ាង ដូចដែលក្រុមប្រឹក្សាភិបាលអនុម័តជាមុនហើយឬនៅ? រួចចេញរបាយការណ៍សវនកម្មផ្ទៃក្នុង ជូនអ្នកប្រើប្រាស់ខាងក្នុង ដើម្បីធ្វើការសម្រេចចិត្ត និងចាត់វិធានការ (Taking in Action)[5]។

ជូនអ្នកប្រើប្រាស់ខាងក្នុង ដើម្បីធ្វើការសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច។ ដូចខាងក្រោម៖

- សវនករផ្ទៃក្នុង : Internal Auditor
- គោលនយោបាយ និងនីតិវិធីផ្ទៃក្នុង : Internal Control Policies & Procedures
- របាយការណ៍សវនកម្មផ្ទៃក្នុង : Internal Audit Report
- អ្នកប្រើប្រាស់ផ្ទៃក្នុង : Internal Users (General Manager, CEO, BOD)។

ការធ្វើសវនកម្មផ្ទៃក្នុង៖ គឺដើម្បីវាយតម្លៃការគ្រប់គ្រងផ្ទៃក្នុង ដំណើរការ ការអនុលោមតាមច្បាប់ និងការពារទ្រព្យសម្បត្តិ។ ដំណើរការសវនកម្មផ្ទៃក្នុងអាចជាឧបករណ៍ដ៏មានសារៈប្រយោជន៍សម្រាប់អាជីវកម្ម ក្នុងការវាយតម្លៃហានិភ័យ និងកំណត់វិធីដែលអាចធ្វើសកម្មភាពដើម្បីកែលម្អការអនុវត្តន៍។ សវនកម្មផ្ទៃក្នុង បានអនុវត្តន៍ដោយក្នុងបុគ្គលិករបស់អង្គភាព។ ប្រសិនបើអាជីវកម្មរបស់អ្នកបានឆ្លងកាត់ការធ្វើសវនកម្មខាងក្នុង និងសវនកម្មខាងក្រៅ ក្រុមសវនកម្មខាងក្រៅ និងទាក់ទងជាមួយក្រុមសវនកម្មខាងក្នុងរបស់អ្នកពេញមួយ

[5] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្នែកទី I ទំព័រទី៣-៥,ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

ដំណើរការសវនកម្ម។ ដូចនេះគណៈកម្មាធិការសវនកម្មផ្ទៃក្នុង គួរតែរៀបចំឯកសារដើម្បីចែករំលែកព័ត៌មានដែលប្រមូលបានពីនីតិវិធីសវនកម្មរបស់ពួកគេ ជាមួយសវនកម្មខាងក្រៅ។

**ខ. សវនកម្មផ្ទៃក្រៅ** (External Audit) គឺជាមុខវិទ្យាមួយបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតពីរបៀបតាមដាន ឆែកឆេរ ប្រមូលភ័ស្តុតាង រួចវាយតម្លៃថា តើអ្នកគ្រប់គ្រងមានបានអនុវត្តន៍ទៅតាមគោលនយោបាយនិងនីតិវិធីគណនេយ្យដើម្បីទទួលបាននូវរបាយការណ៍ហិរញ្ញវត្ថុគួរជាទីទុកចិត្តបាន ដូចដែលក្រុមប្រឹក្សាភិបាលអនុម័តជាមុនហើយឬនៅ?[6]។

រួចចេញរបាយការណ៍សវនកម្មផ្ទៃក្រៅដែលមានលក្ខណៈ ៤យ៉ាងដូចជា៖

១. Unqualified Opinion : ពិតជាស្របតាមស្តង់ដារគណនេយ្យមែន។

២. Qualified Opinion : ពិតជាស្របតាមស្តង់ដារគណនេយ្យមែន ប៉ុន្តែលើកលែង (Except) គណនេយ្យមួយចំនួន។

៣. Disclaimer Opinion : មិនហ៊ានថាស្រប ឬមិនស្របតាមស្តង់ដារ

៤. Adverse Opinion : មិនស្របតាមស្តង់ដារគណនេយ្យទាំងស្រុង។

ជូនអ្នកប្រើប្រាស់ខាងក្រៅ ដើម្បីធ្វើការសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច។ ដូចខាងក្រោម៖

- សវនករផ្ទៃក្រៅ : External Auditor
- គោលនយោបាយ និងនីតិវិធីគ/ណ : Accounting Policies & Procedures
- របាយការណ៍សវនកម្មផ្ទៃក្រៅ : External Audit Report or Audit Opinion
- អ្នកប្រើប្រាស់ផ្ទៃក្រៅ : External Users (Bank, SEC, Shareholders...)

សវនកម្មផ្ទៃក្រៅ៖ ដូចជាក្រុមហ៊ុន CPA (Certified Public Accountants) ឯករាជ្យធ្វើសវនកម្ម-ខាងក្រៅ។ នៅពេលដែលសវនកម្មត្រូវបានបញ្ចប់ របាយការណ៍ត្រូវបានចែកចាយដល់ម្ចាស់ភាគហ៊ុន និងអ្នកពាក់ព័ន្ធនៅខាងក្រៅអង្គភាព។ ខណៈពេលសវនកម្មខាងក្រៅអាចមានភាពខុសប្លែកគ្នា នៅក្នុងអ្វីដែលពួកគេធ្វើសវនកម្ម (របាយការណ៍ហិរញ្ញវត្ថុ ការប្រើប្រាស់មូលនិធិសហព័ន្ធ)។ អត្ថប្រយោជន៍ចម្បងគឺឯករាជ្យភាព និងវត្ថុបំណងរបស់ក្រុមសវនកម្ម។ នេះជាការផ្តល់ឱ្យម្ចាស់ក្រុមហ៊ុន និងអ្នកពាក់ព័ន្ធខាងក្រៅ មានទំនប់ចិត្តបន្ថែមទៀតនៅក្នុងដំណើរការសវនកម្ម និងរបាយការណ៍សង្គតិភាព។

**គ. សវនកម្មរបាយការណ៍ហិរញ្ញវត្ថុ** (Audit of Financial Statements) សវនកម្មរបាយការណ៍ហិរញ្ញវត្ថុពាក់ព័ន្ធសវនករឯករាជ្យដែលនិងរាយការណ៍ថា តើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយស្របទៅនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានអនុវត្តន៍បានដែរឬទេ?[7]។

សវនករត្រូវបំពេញភារៈកិច្ចដូចជា៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យនៃការបញ្ចេញព័ត៌មានមិនពិត ទោះជាការប្លែងបន្លំ ឬកំហុសក៏ដោយ។

[6] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្ទៃកទី I ទំព័រទី៣-៥,ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

[7] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

- ទទួលបានភស្តុតាងសវនកម្មគ្រប់គ្រាន់ ថាតើមានសេចក្តីថ្លែងការណ៍ខុសជាសារវន្តបង្កើតមតិលើរបាយការណ៍ហិរញ្ញវត្ថុ ឬកំណត់មតិថាមិនអាចកំណត់បាន។
- ឧទាហរណ៍៖ ប្រសិនបើអាជីវកម្មខ្នាតតូចមានប្រាក់កម្ចី ឬខ្សែឥណទានជាមួយធនាគារ ធនាគារអាចតម្រូវឱ្យអាជីវកម្មនេះធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។

**ឃ. សវនកម្មប្រតិបត្តិការ** (Operational Audit) គឺពិនិត្យសកម្មភាពរបស់អង្គភាពទាក់ទងនឹងគោល-បំណងដ៏ជាក់លាក់។ សវនករនិងវិភាគដំណើរការ នីតិវិធី និងប្រព័ន្ធ។ ធ្វើការវាយតម្លៃប្រសិទ្ធភាពប្រតិបត្តិការ ប្រសិទ្ធភាព និងផលិតភាព[8]។

អត្ថប្រយោជន៍សវនកម្មប្រតិបត្តិការរួមមានការស្វែងរកឱកាសសម្រាប់ការកែលម្អនិងបង្កើតអនុសាសន៍ ក្រុមហ៊ុនជាច្រើនធ្វើសវនកម្មប្រតិបត្តិការផ្ទៃក្នុង ហើយអង្គភាពអាចទទួលបានអត្ថប្រយោជន៍ពីការធ្វើជាមួយ CPA ដោយសារពួកគេមានចំណេះដឹងជំនាញការបណ្តុះបណ្តាល និងបទពិសោធន៍ក្នុងការអនុវត្តន៍សវនកម្ម។

- ឧទាហរណ៍៖ អាជីវកម្មអាចមានសវនករពិនិត្យផ្នែកធនធានមនុស្សរបស់ខ្លួន។ សវនករនឹងសើបអង្កេតនីតិវិធីរបស់នាយកដ្ឋាន និង របៀបប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។ ហើយរបាយការណ៍ចុងក្រោយគួររួមបញ្ចូលការត្រួតពិនិត្យពេញលេញរបស់នាយកដ្ឋាន និងកំណត់ឱកាសសម្រាប់ការកែលម្អ។

**ង. សវនកម្មប្រព័ន្ធព័ត៌មាន** (Information System Audit) សវនកម្មប្រព័ន្ធព័ត៌មាន វាយតម្លៃការគ្រប់គ្រងនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាន (IT) របស់ក្រុមហ៊ុន។ សវនកម្មនិងកំណត់ថា តើប្រព័ន្ធនិងកំពុងការពារទ្រព្យសម្បត្តិ រក្សាភាពត្រឹមត្រូវនៃទិន្នន័យ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។ អាជីវកម្មអាចទទួលបានអត្ថប្រយោជន៍ពីការធ្វើសវនកម្មប្រភេទនេះ ព្រោះវាអាចជួយកំណត់ឱកាស និងហានិភ័យតម្រឹមការវាយតម្លៃ និងយុទ្ធសាស្ត្រ និងការកែលម្អនីតិវិធីអាជីវកម្ម។ អាជីវកម្មអាចជ្រើសរើសដើម្បីធ្វើសវនកម្មទាំងនេះដោយ ឯករាជ្យ ឬក្នុងអំឡុងពេលរបាយការណ៍ហិរញ្ញវត្ថុ ឬសវនកម្មផ្ទៃក្នុង[9]។

**ច. សវនកម្មប្រាក់បៀវត្សរ៍** (Salary Audit) គឺដើម្បីពិនិត្យដំណើរការនិងរបាយការណ៍ប្រាក់បៀវត្សរ៍។ សវនកម្ម អាចជួយកំណត់អត្តសញ្ញាណកំហុសកែលម្អការអនុលោមតាមច្បាប់ និងការពារអាជីវកម្មពីការក្លែង-បន្លំ។ សវនករផ្ទៃក្នុង ឬសវនករភាគីទីបី ដូចជា CPA អាចធ្វើសវនកម្មប្រាក់បៀវត្សរ៍។ សវនករនិងពិនិត្យបញ្ជីប្រាក់បៀវត្សរ៍របស់ក្រុមហ៊ុនហើយកំណត់ថាតើត្រឹមត្រូវទាន់ពេលវេលានិងពេញលេញដែរឬទេ? ប្រសិនបើពួកគេបានរកឃើញកំហុស សវនករនឹងរកភាពខ្វះខាតក្នុងនីតិវិធីដែលនាំទៅដល់ ឬអាចនាំដល់ភាពមិនត្រឹមត្រូវ។ ការរកឃើញភាពងាយរងគ្រោះណាមួយនឹងអនុញ្ញាតឱ្យអ្នកធ្វើការកែតម្រូវ និងរក្សា ឬកែលម្អ ការអនុលោមតាមច្បាប់។ សម្រាប់ក្រុមហ៊ុនភាគច្រើន សវនកម្មប្រាក់បៀវត្សរ៍ប្រចាំឆ្នាំ ឬពាក់កណ្តាលឆ្នាំត្រូវបានណែនាំ។ សវនកម្មប្រាក់បៀវត្សរ៍ទៀងទាត់ និងអាចជួយក្រុមហ៊ុនរបស់អ្នករក្សាការអនុលោមតាមច្បាប់ និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់អ្នក[10]។

[8] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[9] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[10] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

**ប្រភេទផ្សេងគ្នានៃសវនករក្នុងការធ្វើសវនកម្ម**

សវនករ គឺជាអ្នកដែលត្រូវបានទទួលស្គាល់សិទ្ធិក្នុងការវាយតម្លៃ និងបញ្ជាក់ភាពត្រឹមត្រូវនៃគណនីពាណិជ្ជកម្មរបស់អង្គភាព។ សវនករវាយតម្លៃសកម្មភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលផ្តល់ការងារដល់គេ និងធ្វើឱ្យជាក់លាក់នៃដំណើរការរលូនរបស់អង្គភាព។

សវនករ គឺជាអ្នកឯកទេសសេដ្ឋកិច្ចដែលវិភាគគណនីពាណិជ្ជកម្មសម្រាប់ភាពជាក់លាក់។ ពួកគេភាពត្រឹមត្រូវបានជួលដោយឧស្សាហកម្ម ឬគ្រឹះស្ថានស្វយ័តដើម្បីអនុវត្តន៍សវនកម្មខាងក្នុងនិងសវនកម្មខាងក្រៅ។ សវនករមាន ២ ប្រភេទធំៗដូចខាងក្រោម៖ សវនករខាងក្នុង និងសវនករខាងក្រៅ។

**សវនករខាងក្នុង** (Internal Auditor) គឺភាគច្រើនធ្វើការឱ្យរដ្ឋាភិបាល ឬឧស្សាហកម្មឯករាជ្យ ហើយការងាររបស់ពួកគេគឺពិនិត្យមើលការចាត់ចែងថវិកាមិនត្រឹមត្រូវ និងស្វែងរកមធ្យោបាយកាត់បន្ថយការ ក្លែងបន្លំ និងការកេងបន្លំធនធាន[11]។

គោលបំណងនៃសវនករប្រភេទនេះ គឺធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណេញរបស់ក្រុមហ៊ុនកាត់បន្ថយការខាត់បង់មូលនិធិដែលធ្វើឡើងដោយក្រុមហ៊ុន និងបង្កើតការប្រមូលធនធានដែលកើតឡើងដដែលៗបន្ថែមទៀតទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលទទួលបានប្រាក់ចំណេញ។ ពួកគេតាមដានប្រាក់ចំណូល និងការចំណាយដែលធ្វើឡើងដោយក្រុមហ៊ុន ហើយធ្វើការសរសេរប្រកបដោយធនធានសម្រាប់ក្រុមប្រឹក្សាភិបាល។

**សវនករខាងក្រៅ** (External Auditor) គឺជាអ្នកឯករាជ្យស្វ័យភាពដែលផ្តោតលើសម្មត្ថភាពនៃរបាយការណ៍រូបិយវត្ថុរបស់គ្រឹះស្ថាន ហើយធានាថាវាឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុរបស់សាជីវកម្ម។ សវនករខាងក្រៅមួយចំនួនផ្តល់សេវាកម្មប្រឹក្សាពន្ធ និងអាករដល់អង្គភាព អាជីវកម្ម ក្រុមប្រឹក្សាភិបាល ឬអង្គការនានា។ សវនករត្រូវបានអប់រំឱ្យទទួលស្គាល់ការគំរាមកំហែងដែលជិតមកដល់ និងណែនាំវិធានការប្រុងប្រយ័ត្ន។ តួនាទីរបស់សវនករជាអ្នកផ្តល់ប្រឹក្សា ទាំងខាងក្នុង និងខាងក្រៅ គឺត្រូវបានជួសជួលលើការផ្តល់ការវាសតម្លៃដោយមិនលម្អៀង និងការប៉ាន់ប្រមាណប្រកបដោយចំណេះដឹងអំពីរបៀបដែលការអនុវត្តន៍ និងសកម្មភាពបច្ចុប្បន្នអាចត្រូវបានបង្កើតឡើង។ ជាទូទៅ គោលដៅរបស់សវនកររួមមាន ការបង្កើតផលិតភាពប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យ និងការអនុលោមតាមការត្រួតពិនិត្យ។[12]

ក្រមសីលធម៌របស់សវនករ ត្រូវឈរលើមូលដ្ឋានដូចខាងក្រោម៖

- ឯករាជ្យភាព : Independence
- សមត្ថភាពអាជីប : Professional Competence
- ទំនួលខុសត្រូវ : Responsibility
- ការសម្ងាត់ : Confidence
- សុចរិត និងស្មោះត្រង់ : Integrity & Royalty

ជាទូទៅក្រមសីលធម៌ ដើរតួនាទីជាមូលដ្ឋានក្នុងដំណើរការសវកម្មគ្រប់ប្រភេទ។ ចំណុចសំខាន់គឺថា សវនករត្រូវតែធ្វើសកម្មភាពដោយក្រមសីលធម៌ជានិច្ច ដើម្បីរក្សាភាពជឿទុកចិត្តពីអ្នកដែលពួកគេធ្វើការឱ្យ

[11] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្នែកទី1(ទំព័រទី២២-២៧),ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)
[12] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្នែកទី1(ទំព័រទី២២-២៧),ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

និងដើម្បីការពារអង្គភាពដែលពួកគេធ្វើសវនកម្ម។ លើសពីនេះ គ្រប់ក្រមសីលធម៌វិជ្ជាជីវៈក្នុងសវនកម្មតម្រូវឱ្យសវនករអនុវត្តន៍ការយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តន៍ភារៈកិច្ចរបស់ខ្លួន។ មានន័យថា សវនករត្រូវប្រើប្រាស់ជំនាញសវនកម្ម និងចំណេះដឹងដែលពួកគេទទួលបានតាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍ដើម្បីអនុវត្តន៍ការងាររបស់របស់ពួកគេដោយត្រឹមត្រូវ។ មួយទៀតក្រមសីលធម៌វិជ្ជាជីវៈទាំងអស់ក្នុងសវនកម្មតម្រូវឱ្យសវនកររក្សាការសម្ងាត់ គឺសវនករមិនត្រូវបង្ហាញព័ត៌មានណាមួយអំពីអតិថិជនរបស់ពួកគេ ឬអង្គភាពដែលពួកគេបានធ្វើសវនកម្មសម្រាប់ពួកគេដោយគ្មានការយល់ព្រមពីអតិថិជននោះទេ។ ពិសេសជាងនេះទៀតក្រមសីលធម៌នៃវិជ្ជាវៈក្នុងសវនកម្ម ជួយធានាថាសវនករផ្តល់សេវាកម្មគុណភាពខ្ពស់ដល់អតិថិជនរបស់ពួកគេ និងការពារផលប្រយោជន៍ជាសាធារណៈដោយធានាថាសវនករមានភាពឯករាជ្យនៅក្នុងការងាររបស់ពួកគេ។

**ភាពរំពឹងទុករបស់សវនករ**

អ្វីដែលត្រូវបានរំពឹងទុករបស់សវនករ អាចខុសគ្នាពីស្ថាប័នមួយទៅស្ថាប័នមួយ ប៉ុន្តែតួនាទីសំខាន់មួយចំនួនដែលសវនករដើរក្នុងស្ថាប័នណាមួយរួមមានៈ

- ការវាយតម្លៃ និងការយល់ដឹងអំពីរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាព
- ធ្វើឱ្យប្រាកដថាធនធានមិនត្រូវបានរំខាន
- ការទទួលស្គាល់ប្រសិនបើ កន្លែងដែលនីតិវិធីមិនដំណើរការ ដូចដែលវាត្រូវបានសន្មត់ថា និងផ្តល់ដំបូន្មានលើការផ្លាស់ប្តូរត្រឹមត្រូវដែរត្រូវធ្វើតាម
- ធ្វើឱ្យប្រាកដដំណើរការ គោលនយោបាយ ច្បាប់ បទបញ្ញត្តិត្រូវបានអនុវត្តន៍ និងបំពេញឯកសារការងារសវនកម្ម និងអនុស្សរណៈដោយចងក្រងឯកសារ ការធ្វើតេស្តសវនកម្ម និងការរកឃើញ
- ការពារកេរ្តិ៍ឈ្មោះរបស់អង្គភាពដោយរក្សាព័ត៌មានសម្ងាត់ និងការវាយតម្លៃកម្រិតនៃការកំរាមកំហែងផ្នែកហិរញ្ញវត្ថុនៅក្នុងអង្គភាព
- បន្ថែមលើលទ្ធផលក្រុមដោយស្វាគមន៍នូវតម្រូវការងារថ្មី និងចម្រុះ។ ស្វែងរកឱកាសថ្មីដើម្បីបន្ថែមលើសារៈសំខាន់ដល់អង្គភាព។ ជួយអ្នកដ៏ទៃឱ្យសម្រេចបានលទ្ធផលការងារដែលពាក់ព័ន្ធ និងក្នុងករណីចាំបាច់។
- នៅចុងបញ្ចប់នៃសវនកម្ម សវនករក៏អាចស្នើសុំនៃការណែនាំអំពីគោលបំណងសម្រាប់ការកែលម្អរបាយការណ៍ហិរញ្ញវត្ថុ និងការគ្រប់គ្រងផ្ទៃក្នុង ដើម្បីទទួលបានអត្ថប្រយោជន៍ច្រើនបំផុតនៃដំណើរការ និងផលិតភាពរបស់ក្រុមហ៊ុន[13]។

**ជំនាញដែលសវនករគួរមាន**

- ការសង្កេតតាមការត្រួតពិនិត្យ
- សមត្ថភាពក្នុងការយកចិត្តទុកដាក់លើរាល់ព័ត៌មានលម្អិតតូចតាច
- ជំនាញបច្ចេកវិទ្យា
- ជំនាញអន្តរបុគ្គល

[13] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

- ការយល់ដឹងទូលំទូលាយអំពីអាជីវកម្ម។

**ភស្តុតាងសវនកម្ម ដែលទទួលបានតាមរយៈនីតិវិធីមួយចំនួន**

ភស្តុតាងសវនកម្ម ត្រូវបានប្រមូលតាមរយៈនីតិវិធីសវនកម្ម។ នីតិវិធីទាំងនោះត្រូវបានចាត់ថ្នាក់ជានីតិវិធីវាយតម្លៃហានិភ័យ និងនីតិវិធីសវនកម្ម[14]។

- អធិការកិច្ច : Inspection
- ការសង្កេត : Observation
- ការបញ្ជាក់ខាងក្រៅ : External Confirmation
- ការគណនាឡើងវិញ : Recalculation
- ការសម្តែងឡើងវិញ : Replay
- នីតិវិធីវិភាគ : Analysis Procedure
- ការសាកសួរ។ : Inquiry

ភស្តុតាងសវនកម្ម គឺជាផ្នែកសំខាន់មួយនៃដំណើរការសវនកម្មទាំងមូល ដែលបាននិយាយថាវាគ្រាន់តែជាការសំខាន់ផងដែរ ក្នុងការពិចារណាពីរបៀបដែលភស្តុតាងត្រូវបានប្រមូល កន្លែងដែលវាមានប្រភពមកពីដំណើរការគំរូសវនកម្ម និងថាតើមានភស្តុតាងគ្រប់គ្រាន់ដើម្បីអនុម័ត ឬបដិសេធការអះអាងដែលធ្វើឡើងដោយក្រុមហ៊ុនមុខពេលធ្វើសវនកម្ម។

**គុណសម្បត្តិនៃការទទួលបាន ភស្តុតាងសវនកម្ម**

- ភស្តុតាងសវនកម្មណាមួយដែលទទួលបានត្រូវតែគ្រប់គ្រាន់ និងសមស្រប
- ភាពគ្រប់គ្រាន់វាស់វែងបរិមាណនៃភស្តុតាងសវនកម្ម ខណៈដែលភាពសមស្របសំដៅទៅលើគុណភាពនៃភស្តុតាងសវនកម្ម
- ភាពគ្រប់គ្រងនៃភស្តុតាងសវនកម្ម ត្រូវបានប៉ះពាល់ដោយទាំងហានិភ័យនៃការបញ្ចេញមតិមិនត្រឹមត្រូវ ឬហានិភ័យដែលទាក់ទងនិងការគ្រប់គ្រង និងគុណភាពនៃភស្តុតាងសវនកម្មដែលទទួលបាន
- ភាពសមស្របភស្តុតាងសវនកម្មត្រូវបានប៉ះពាល់ដោយពាក់ព័ន្ធនិងភាពជឿជាក់របស់វា
- ភាពអាចជឿជាក់បានសំដៅលើរបៀបដែលភស្តុតាងត្រូវបានប្រមូល និងប្រភពរបស់វា។

**សារៈសំខាន់នៃភស្តុតាងសវនកម្ម**

ភស្តុតាងសវនកម្មមានសារៈសំខាន់សម្រាប់សវនករណាមួយ ដើម្បីបញ្ជាក់ការសន្និដ្ឋានរបស់គាត់។

- មតិដែលបានបង្ហាញដោយសវនករបន្ទាប់ពីធ្វើសវនកម្ម គឺអាស្រ័យលើភស្តុតាង ដែលប្រមូលបាន។
- ប្រសិនបើរកឃើញពីសវនកម្មបានជំទាស់សវនករ និងពឹងផ្អែកលើកម្លាំងនៃភស្តុតាងលើសវនកម្មដើម្បីគាំទ្របតិរបស់ពួកគេ។ ពិសេសក្រុមហ៊ុនដែលធ្វើការជួញដូរជាសាធារណៈត្រូវតែធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេដល់វិនិយោគិនរៀងរាល់ឆ្នាំ។

[14] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

របាយការណ៍សវនកម្ម រួចទាំងនោះមានផ្ទុកនូវព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ដែលវិនិយោគិនប្រើដើម្បីធ្វើការសម្រេចចិត្តថាតើត្រូវដាក់ប្រាក់របស់ពួកគេឬអត់។ ដូច្នេះហើយ ភាពពេញលេញ និងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនោះគឺជាអាទិភាពខ្ពស់។ ការអះអាងណាមួយដែលក្រុមហ៊ុនធ្វើអំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួនត្រូវតែបានបញ្ជាក់ដោយភស្តុតាងខាងក្រៅ (ដូចជារបាយការណ៍ធនាគារ) ឬសវនករត្រូវធ្វើការវិភាគដោយខ្លួនឯងដើម្បីផ្ទៀងផ្ទាត់ភាពស្របច្បាប់ នៃព័ត៌មានដែលផ្តល់ដោយក្រុមហ៊ុន។

**គោលបំណងសំខាន់ៗនៃក្រមសីលធម៌វិជ្ជាជីវៈសវនកម្ម**

- ការធានានូវឯករាជ្យភាពរបស់សវនករពីអតិថិជន
- ការពារផលប្រយោជន៍ជាសាធារណៈ
- ការរក្សាភាពត្រឹមត្រូវនៃវិជ្ជាជីវៈ
- ការប្រកាន់ភ្ជាប់នូវស្តង់ដារខ្ពស់នៃវិជ្ជាជីវៈ

ហានិភ័យសវនកម្ម គឺជាហានិភ័យទាំងឡាយណាដែលសវនករស្វែងរកមិនឃើញកំហុសឬការក្លែងបន្លំនៅពេលពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុរបស់អតិថិជន ដើម្បីកាត់បន្ថយកម្រិតហានិភ័យសវនកម្ម សវនករអាចបង្កើតចំនួននីតិវិធីសវនកម្ម។ ការកាត់បន្ថយហានិភ័យសវនកម្មដល់កម្រិតតិចតួចគឺជាផ្នែកសំខាន់នៃមុខងារសវនកម្ម ដោយសារអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុពឹងផ្អែកលើការធានារបស់សវនករ នៅពេលពួកគេអានរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នមួយ។

**ក្នុងការអនុវត្តន៍ជាក់ស្តែង សវនករបានកំណត់ហានិភ័យសវនកម្មចេញជា ៣ប្រភេទៈ**

១. ហានិភ័យមានប្រភពពីក្រៅអង្គភាព : Inherent Risk
- ហានិភ័យសេដ្ឋកិច្ចពិភពលោក : Global Economic Risk
- ហានិភ័យសេដ្ឋកិច្ចប្រទេស : Country Economic Risk
- ហានិភ័យសេដ្ឋកិច្ចវិស័យឧស្សាហកម្ម : Industry Economic Risk។

២. ហានិភ័យមានប្រភពពីប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងអង្គភាព : Control Risk
- ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង : Internal Control System
- ប្រព័ន្ធបញ្ជីគណនេយ្យ : Accounting System។

៣. ហានិភ័យមានប្រភពពីក្នុងអង្គភាពស្ថិតនៅទីកំបាំង : Detection Risk។

Detection Risk គឺជាហានិភ័យទាំងឡាយណាដែលកើតឡើង ដោយសារការរៀបចំរបស់អ្នកគ្រប់គ្រងហើយស្ថិតនៅទីកំបាំងទោះសវនករខំស្វាក់ចាប់ក៏បានតែមួយចំនួនហើយមួយចំនួយទៀតនៅទីកំបាំងដ៏ដែល។ ដូចនេះ ដើម្បីកាត់បន្ថយហានិភ័យនៃកំហុស និងការក្លែងបន្លំនៅក្នុងកំណត់ត្រាហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនទៅកម្រិតទាបសមរម្យវាជាទំនួលខុសត្រូវផ្លូវច្បាប់របស់ក្រុមហ៊ុនសវនកម្ម ក្នុងការផ្តល់នូវមតិត្រឹមត្រូវលើរបាយ-ការណ៍ហិរញ្ញវត្ថុ ដោយសារភាគីពាក់ព័ន្ធជាច្រើនដូចជា ម្ចាស់ភាគហ៊ុន អ្នកផ្តល់ប្រាក់កម្ចី និងអ្នកវិនិយោគពឹងផ្អែកលើភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើការសម្រេចចិត្តរបស់ពួកគេ។ ហានិភ័យសវនកម្មក៏ជួយសវនករក្នុងការដាក់យុទ្ធសាស្ត្រសវនកម្មសម្រាប់ស្ថាប័នជាក់លាក់មួយ[15]។

[15] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្ទៃក្នុងទី(ទំព័រទី២២-២៧),ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

**គោលបំណងនៃរបាយការណ៍សវនកម្មរួមមាន៖**

- ដើម្បីពិនិត្យមើលវិធានការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននៅនឹងកន្លែង
- ដើម្បីផ្ទៀងផ្ទាត់ការគណនា និងតុល្យភាពនៃសៀវភៅគណនី និងឯកសារជំនួយ
- ត្រូវប្រាកដថាតើមានភាពស្មោះត្រង់ និងមានភាពយុត្តិធម៌នៅក្នុងលទ្ធផលប្រតិបត្តិការដែលបង្ហាញដោយរបាយការណ៍ប្រាក់ចំណូល ក៏ដូចជាទីតាំងហិរញ្ញវត្ថុដែលបានបង្ហាញដោយតារាងតុល្យការ។
- ការរកឃើញ និងការទប់ស្កាត់ការក្លែងបន្លំ ដូចជាការក្លែងបន្លំសាច់ប្រាក់ និងទំនិញរបស់ក្រុមហ៊ុន ការក្លែងបន្លំគណនី ឬការក្លែងបន្លំដោយការវាយតម្លៃក្រោម ឬលើសភាគហ៊ុន។

សវនករខាងក្នុង ជាធម្មតាសហការជាមួយសវនករខាងក្រៅជាប្រចាំជានិច្ចនិង ដើម្បីផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារ។ បន្ទាប់ពីគោលបំណងខាងលើទាំងអស់ត្រូវបានសម្រេច ហើយបន្ទាប់មកសវនករអាចបញ្ចេញមតិសមហេតុសមផលលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ដូចនេះ ប្រភេទនៃមតិដែលបានផ្តល់ និងបានជះឥទ្ធិពលធាតុនីមួយៗដូចដែលបានរាយការណ៍ខាងលើ។

**សារៈសំខាន់នៃរបាយការណ៍សវនកម្មអាចត្រូវបានវិនិច្ឆ័យដូចខាងក្រោម៖**

- លទ្ធផលចុងក្រោយនៃសវនកម្ម
- យោបល់របស់សវនករលើគណនី
- ការឆ្លុះបញ្ចាំងពីការងាររបស់សវនករ
- វិធានការទទួលខុសត្រូវរបស់សវនករ
- ប្រើជាប្រភពភស្តុតាងដែលអាចទុកចិត្តបាន
- ដំបូន្មានដល់អ្នកគ្រប់គ្រង

ក្នុងករណីសវនករខាងក្នុង វាអាចទៅរួចដែលអ្នកគ្រប់គ្រងអាចពិគ្រោះជាមួយសវនករខាងក្រៅ និងស្វែងរកដំបូន្មានលើបញ្ហាបច្ចេកទេសមួយចំនួន។ យ៉ាងណាក៏ដោយគាត់គួរយកចំណុចខ្វះខាតរបស់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមកជូនអ្នកគ្រប់គ្រង។ ព្រោះប្រសិនបើមានចំណុចខ្វះខាតនៅក្នុងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង នោះវាប៉ះពាល់ដល់លក្ខណៈនិងវិសាលភាពនៃនីតិវិធីសវនកម្ម។

## ២.២ សមាសធាតុនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

### ២.២.១ និយមន័យនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយប្រភេទដែលរៀបចំឡើង ដោយផ្អែកទៅតាមវិធីសាស្រ្តគណនេយ្យ ដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ នៅពេលកំណត់ជាក់លាក់មួយ[16]។

របាយការណ៍ហិរញ្ញវត្ថុ គឺសំដៅលើទំនាក់ទំនងព័ត៌មានហិរញ្ញវត្ថុ ដូចជារបាយការណ៍ហិរញ្ញវត្ថុទៅកាន់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដូចជាអ្នកវិនិយោគ និងម្ចាស់បំណុលជាដើម[17]។

[16] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[17] www.khsearch.com/qna/17946(ទស្សនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣)

របាយការណ៍ហិរញ្ញវត្ថុ គឺជាដំណើរការនៃការបង្កើតរបាយការណ៍ ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នមួយទៅកាន់អ្នកគ្រប់គ្រង អ្នកវិនិយោគ និងរដ្ឋាភិបាល[18]។

សមាសធាតុនៃរបាយការណ៍ហិរញ្ញវត្ថុ ជាទូទៅបានផ្តល់នូវព័ត៌មានដែលមានសារៈសំខាន់ និងមានប្រយោជន៍សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ទៅលើរបាយការណ៍របស់អង្គភាពមួយ ។ ហើយរបាយការណ៍ហិរញ្ញវត្ថុក៏ជារបាយការណ៍មួយ ដែលមានសារៈប្រយោជន៍ខ្លាំងបំផុតនូវក្នុងដំណើរការនៃគណនេយ្យ ពីព្រោះរបាយការណ៍ហិរញ្ញវត្ថុ គឺជាមធ្យោបាយមួយនៅក្នុងការទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ ដើម្បីឱ្យគេកាន់តែមានចំណាប់អារម្មណ៍មកលើវា។ ក្នុងមូលដ្ឋានគណនេយ្យរបាយការណ៍ហិរញ្ញវត្ថុមួយដ៏ពេញលេញត្រូវមានរបាយការណ៍ ៤យ៉ាងដូចជា៖

**១. របាយការណ៍តុល្យការ** (Balance Sheet) :គឺជារបាយការណ៍ហិរញ្ញវត្ថុដែលផ្តល់នូវរូបភាពពិតនៃក្រុមហ៊ុនមាន និងជំពាក់ព្រមទាំងចំនួនទឹកប្រាក់ដែលបានវិនិយោគដោយភាគទុនិក។ តារាងតុល្យការអាចត្រូវបានប្រើជាមួយរបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀតដើម្បីធ្វើការវិភាគជាមូលដ្ឋាន ឬគណនាសមាមាត្រហិរញ្ញវត្ថុ។

- ទ្រព្យសកម្ម Assets : គណនីនៅក្នុងផ្នែកនេះត្រូវបានរាយបញ្ជីកំពូលទៅបាត តាមលំដាប់លំដោយនៃសាច់ប្រាក់ងាយស្រួលរបស់ពួកគេ។ ពួកគេត្រូវបានបែងចែកទៅជាទ្រព្យសកម្មបច្ចុប្បន្ន ដែលអាចបំប្លែងទៅជាសាច់ប្រាក់ក្នុងរយៈពេលមួយឆ្នាំ ឬតិចជាងនេះ និងទ្រព្យសកម្មមិនមែនបច្ចុប្បន្ន ឬរយៈពេលវែងដែលមិនអាច។
- បំពុល Liabilities : ទំនួលខុសត្រូវ គឺជាប្រាក់ដែលក្រុមហ៊ុនជំពាក់ភាគីខាងក្រៅ ចាប់ពីវិក័យបត្រដែលខ្លួនត្រូវបង់ទៅឱ្យអ្នកផ្គត់ផ្គង់ ដល់ការប្រាក់លើមូលបត្របំណុលដែលចេញដោយម្ចាស់បំណុលជួល ថ្លៃទឹកភ្លើង និងប្រាក់ខែបុគ្គលិក។ និងបំណុលបច្ចុប្បន្នដល់ពេលកំណត់រយៈពេលមួយឆ្នាំ ហើយត្រូវបានចុះបញ្ជីតាមលំដាប់នៃកាលវិយបរិច្ឆេទកំណត់របស់ពួកគេ។ ម្យ៉ាងវិញទៀត បំណុលរយៈពេលវែងត្រូវដល់ពេលណាមួយបន្ទាប់ពីមួយឆ្នាំ។
- ភាគហ៊ុនិក Shareholder Equity : គឺជាប្រាក់ដែលកើតចេញពីម្ចាស់អាជីវកម្ម ឬម្ចាស់ភាគហ៊ុនរបស់ខ្លួន។ វាត្រូវបានគេទទួលស្គាល់ថាជាទ្រព្យសកម្មសុទ្ធ ព្រោះវាស្មើរនិងទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនដល់បំណុលរបស់ខ្លួនឬបំណុលដែលខ្លួនជំពាក់ចំពោះអ្នកមិនមែនម្ចាស់ភាគហ៊ុន[19]។

សារៈសំខាន់នៃតារាងតុល្យការ គឺដោយមិនគិតពីទំហំនៃក្រុមហ៊ុន ឬឧស្សាហកម្មដែលខ្លួនដំណើរការវាមានអត្ថប្រយោជន៍ជាច្រើននៃតារាងតុល្យការ។ តារាងតុល្យការកំណត់ហានិភ័យនៃរបាយការណ៍ហិរញ្ញវត្ថុនេះរាយបញ្ជីអ្វីគ្រប់យ៉ាងដែលក្រុមហ៊ុនមាន និងបំណុលទាំងអស់របស់ខ្លួន។ ក្រុមហ៊ុនមួយនិងអាចវាយតម្លៃ

[18] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[19] www.khsearch.com/qna/17946( ទស្សនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ )

បានយ៉ាងឆាប់រហ័ស ថាតើខ្លួនអាចខ្ចីប្រាក់ច្រើនពេក ឬថាតើទ្រព្យសម្បត្តិដែលខ្លួនមានមិនគ្រប់គ្រាន់ ឬថាតើមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញតម្រូវការបច្ចុប្បន្ន។

- តារាងតុល្យការកំណត់ក៏ត្រូវបានប្រើផងដែរ ដើម្បីជានាដើមទុន
- តារាងតុល្យការអាចទាក់ទាញ និងរក្សាទេពកោសល្យ។

**២. របាយការណ៍លទ្ធផល** (Income Statement) : ជារបាយការណ៍កត់ត្រានៃប្រាក់ចំណេញនិងខាតរបស់ក្រុមហ៊ុនក្នុងរយៈពេលឆ្នាំហិរញ្ញវត្ថុ។ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន គឺបានមកពីការកាត់ប្រាក់ចំណូលសរុបពីការចំណាយទាំងអស់ដែលកើតឡើងសម្រាប់សកម្មភាពប្រតិបត្តិការ និងសកម្មភាពមិនដំណើរការ។ អ្នកវិនិយោគិន គណនេយ្យករនិងម្ចាស់អាជីវកម្មជាទៀងទាត់ពិនិត្យមើលរបាយការណ៍ប្រាក់ចំណូលដើម្បីមើលថាតើពួកគេស្ថិតនៅលើផ្លូវសម្រាប់គោលដៅដែលរំពឹងទុករបស់គេដែរឬទេ។ របាយការណ៍ប្រាក់ចំណូលត្រូវបានពិនិត្យដើម្បីកំណត់ចំណុចខ្វះខាតនៃយុទ្ធសាស្ត្រដាក់លាក់មួយនិងជម្រុញវាឱ្យដើរក្នុងទិសដៅត្រឹមត្រូវ[20]។ របាយការណ៍លទ្ធផលរួមបញ្ចូលធាតុសំខាន់ៗដូចខាងក្រោម ៖

- ផលចំណូល Revenue : គឺជាការហូរចូលនៃទ្រព្យសម្បត្តិ (ដូចជា សាច់ប្រាក់) ដែលបានមកពីការលក់ផលិតផល ឬ ការផ្តល់សេវាកម្មទៅឱ្យអតិថិជន[21]។
- បន្ទុកចំណាយ Expense : គឺជាការចាយវាយដែលបានលះបង់ ឬក៏ប្រើប្រាស់នៅក្នុងការបំរើអតិថិជនជាដើម។ ប្រសិនបើចំណូលនូវការិយបរិច្ឆេទមួយធំជាងចំណាយនូវក្នុងការិយបរិច្ឆេទដដែល នោះប្រាក់ចំណេញសុទ្ធ Net Income នឹងកើតមានឡើង។ ផ្ទុយមកវិញបើបន្ទុកចំណាយធំជាងបន្ទុក ចំណូលនោះក្រុមហ៊ុនយើងនឹងទទួលរងនូវការខាតបង់ Net Loss ហើយវាគឺជាប្រតិបត្តិការដែលគ្មានលទ្ធភាពរកប្រាក់ចំណេញ។
- ផលចំណេញ Gain : គឺជាការកើនឡើងនៅទ្រព្យសកម្មដែលទទួលបាន មកពីការធ្វើសកម្មផ្សេងៗរបស់សហគ្រាស។ វាលើកលែងតែការកើនឡើងពីការបណ្តាក់ទុនបន្ថែមពីម្ចាស់អាជីវកម្មផ្ទាល់ ។
- ការខាតបង់ Losses: គឺជាលទ្ធផលមួយដែលធ្វើឱ្យមានការថយចុះនូវទ្រព្យសកម្មដែលវាកើតឡើង ដោយសារតែការធ្វើសកម្មភាពផ្សេងៗរបស់សហគ្រាសលើកលែងតែការថយចុះនោះកើតឡើងដោយសារតែការបែងចែងភាគលាភរបស់ម្ចាស់អាជីវកម្មផ្ទាល់។ ទំនាក់ទំនងរវាងផលចំណេញ ឬការខាតបង់មានដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ចំណេញពិត (ខាតពិត) | = | ផលចំណូល | - | បន្ទុកចំណាយ |
| Net Income (Net Loss) | = | Revenue | - | Expense |

[20] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[21] www.khsearch.com/qna/17946(ទស្សនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣)

សារៈសំខាន់នៃរបាយការណ៍ប្រាក់ចំណូល នៅគ្រប់សកម្មភាពអាជីវកម្ម ការរៀបចំរបាយការណ៍ប្រាក់-ចំណូល គឺជាកិច្ចការប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ នេះជាមូលហេតុដ៏អស្ចារ្យមួយចំនួនដែលបានរៀបចំរបាយការណ៍ប្រាក់ចំណូល គឺជាកិច្ចការសំខាន់បែបនេះនៅគ្រប់ស្ថាប័នដោយមិនគិតពីទំហំ៖

- ជួយក្នុងការសម្រេចចិត្តកាន់តែប្រសើរឡើង
- តាមដានប្រាក់ចំណេញរបស់ក្រុមហ៊ុន
- របាយការណ៍សំខាន់សម្រាប់ការអនុលោមតាមច្បាប់។

**៣. របាយការណ៍មូលធន និងទ្រព្យម្ចាស់** (Statement of Equity Change) : របាយការណ៍នៃភាគហ៊ុនមានភាពខុសគ្នារវាងទ្រព្យសកម្មសរុប និងបំណុលសរុប ហើយជាធម្មតាត្រូវបានវាស់វែង ជាប្រចាំខែ ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។ ភាគហ៊ុនអាចកើតឡើងបានលុះត្រាមានការរួមចំណែកដើមទុនកាន់តែច្រើនដោយម្ចាស់អាជីវកម្ម ឬអ្នកវិនិយោគ ឬប្រសិនប្រាក់ចំណេញអាជីវកម្មមានភាពប្រសើរនៅពេលវាលក់ផលិតផលកាន់តែច្រើន ឬបង្កើតប្រាក់ចំណេញដោយការទប់ស្កាត់ការចំណាយ[22]។

សារៈសំខាន់នៃរបាយកាណ៍ភាគហ៊ុនរបស់ម្ចាស់ភាគហ៊ុន វាជួយអ្នកទាក់ទាញដល់វិនិយោគិនខាងក្រៅដែរចង់ដាក់ទុនទៅក្នុងសហគ្រាសរបស់អ្នក និងផលប្រយោជន៍ដល់ម្ចាស់ភាគហ៊ុនសម្រាប់រយៈពេលវែង និងបង្ហាញពីផលប៉ះពាល់នៃការធ្លាក់ចុះភាគហ៊ុនជាដើម។

- អាចជួយធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ
- អាចប្រាប់ពីរបៀបដែលអ្នកកំពុងដំណើរការអាជីវកម្មរបស់អ្នក
- អាចជួយឱ្យអ្នកឆ្លងកាត់ការលំបាកផ្នែកហិរញ្ញវត្ថុ។

**៤. របាយការណ៍លំហូរសាច់ប្រាក់** (Statement of Cash Flow) : ជារបាយការណ៍ហិរញ្ញវត្ថុធម្មតាដែលប្រាប់អ្នកពីចំនួនទឹកប្រាក់ដែលអ្នកមាននៅក្នុងដៃសម្រាប់រយៈពេលជាក់លាក់មួយ របាយការណ៍ប្រាក់ចំណូលគឺល្អបំផុតសម្រាប់បង្ហាញអ្នកពីចំនួនប្រាក់ដែលអ្នកបានចំណាយ និងរកបាននោះ ពួកគេមិនចាំបាច់ប្រាប់អ្នកពីចំនួនទឹកប្រាក់ដែលអ្នកមានក្នុងដៃសម្រាប់រយៈពេលជាក់លាក់ណាមួយនោះទេ។ របាយការណ៍សាច់ប្រាក់ធ្វើការកែតម្រូវទៅលើព័ត៌មានដែលបានកត់ត្រានៅលើរបាយការណ៍ប្រាក់ចំណូលរបស់អ្នក ហើយអ្នកនិងឃើញលំហូរសាច់ប្រាក់សុទ្ធរបស់អ្នកគឺចំនួនសាច់ប្រាក់ច្បាស់លាស់ដែលអ្នកមានក្នុងដៃសម្រាប់រយៈពេលនោះ[23]។

សារៈសំខាន់នៃរបាយការណ៍លំហូរសាច់ប្រាក់ ដរាបណាអ្នកប្រើគណនីបង្គររបាយការណ៍លំហូរសាច់-ប្រាក់ គឺជាផ្នែកសំខាន់នៃការវិភាគហិរញ្ញវត្ថុសម្រាប់ហេតុផល ៣យ៉ាងដូចជា៖

- លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ (Operating Activities) គឺជាការបង្ហាញពីសាច់ប្រាក់ងាយស្រួលរបស់អ្នក។
- លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ (Investing Activities) គឺជាការបង្ហាញអ្នកនូវការផ្លាស់ប្តូរនៅក្នុងទ្រព្យសកម្ម បំណុលនិងសមធម៌ក្នុងទម្រង់នៃលំហូរសាច់ប្រាក់ និងសាច់ប្រាក់ដែរបានរក្សាទុក[24]។

[22] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[23] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[24] www.khsearch.com/qna/17946( ទស្សនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ )

- លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន (Financing Activities) គឺការអនុញ្ញាតឱ្យអ្នកព្យាករណ៍លំហូរសាច់ប្រាក់នាពេលអនាគត់។

**៥. កំណត់បង្ហាញនៃរបាយការហិរញ្ញវត្ថុ** (Note to Financial Statement) : គឺជាតម្រូវការនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) និងជាលេខយោងនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ពួកគេរាយបញ្ជីសន្មត់ វិធីសាស្រ្ត និងគោលនយោបាយដែលប្រើដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ហើយកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ផ្តល់ឱ្យអ្នកនូវព័ត៌មានដែលត្រូវការសម្រាប់ការយល់ដឹងត្រឹមត្រូវ និងការបកស្រាយនៃកំណត់ត្រាគណនេយ្យ[25]។

**៦. របាយការណ៍របស់សវនករ** (Audit Report):សំដៅលើលិខិតឬឯកសារដែលសរសេរដោយសវនករឬគណនេយ្យករ បន្ទាប់ពីដំណើរការសវនកម្មគណនេយ្យដែលគិតថា តើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដូចដែលបានបង្ហាញស្របតាមគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP) ដែរឬទេ[26]។

**២.២.២ ប្រវត្តិនៃរបាយការណ៍ហិរញ្ញវត្ថុ**

គណនេយ្យហិរញ្ញវត្ថុទំនើបតាមដានដើមកំណើតដ៏វែងឆ្ងាយរបស់ខ្លួនរហូតដល់ សតវត្សរ៍ទី១៥ វាទាំងអស់បានចាប់ផ្តើមនៅពេលដែលព្រះសង្ឃអ៊ីតាលី Luca Pacilio ដែលក្រោយមកត្រូវបានគេស្គាល់ថាជា "បិតានៃគណនេយ្យ" បានណែនាំគំនិតនៃឥណពន្ធនិងឥណទានដែលបន្តបង្កើតមូលដ្ឋានគ្រឹះនៃគណនេយ្យទំនើប។ ទោះជាយ៉ាងណាក៏ដោយមុនឆ្នាំ ១៩១៧ បួនឆ្នាំបន្ទាប់ពីការធ្វើវិសោធនកម្មលើកទី ១៦ ត្រូវបានផ្តល់សច្ចាប័នថា Federal Reserve កំណត់ស្តង់ដារដំបូងសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុដែលនាំទៅដល់តម្រូវការសម្រាប់ពលរដ្ឋអាមេរិច និងសាជីវកម្មទាំងអស់ក្នុងការបង់ពន្ធលើប្រាក់ចំណូល។ ហើយបន្ទាប់ពីការដួលរលំសេដ្ឋកិច្ចដ៏មហន្តរាយនៃចុងទសវត្សរ៍ឆ្នាំ ១៩២០ ដែលនាំឱ្យមានការបរាជ័យនៃទីផ្សារភាគហ៊ុន ក៏ដូចជាប្រព័ន្ធធនាគារតម្រូវការសវនកម្មត្រូវបានដាក់នៅលើសាជីវកម្មអាមេរិច។

នៅដើមឆ្នាំ ១៩៣៣ មានការផ្លាស់ប្តូរទម្រង់និងមុខងារនៃរបាយការណ៍ហិរញ្ញវត្ថុដែលមានវិធានការច្បាប់ និងនិយតកម្មសំខាន់ៗនៃទម្រង់របាយការណ៍ហិរញ្ញវត្ថុដែលយើង ប្រើសព្វថ្ងៃនេះរួមទាំងរបាយការណ៍ប្រាក់ចំណូលសាមញ្ញ តារាងតុល្យការ និងរបាយការណ៍លំហូរសាច់ប្រាក់ដែលគ្របដណ្តប់លើរបាយការណ៍ហិរញ្ញវត្ថុទំនើប។ រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៨០ មុនពេលការមកដល់នៃកម្មវិធីហិរញ្ញវត្ថុ ការធ្វើគណនេយ្យនិងគណនេយ្យត្រូវបានធ្វើឡើងដោយដៃនៅលើសៀវភៅបញ្ជីក្រដាស។ នេះតម្រូវឱ្យមានការសង្កេតនិងប្រសិទ្ធភាពយ៉ាងច្រើន ដោយសារគោលដៅចុងក្រោយគឺបង្កើតរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើការអនុលោមតាម។

ជាលទ្ធផល ដំណោះស្រាយផែនការធនធានសហគ្រាសធំ (ERP) បានចាប់ផ្តើមកើនឡើងដល់ភាពលេចធ្លោនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដល់ ១៨៩០ ដែលដឹកនាំដោយអ្នកដឹកនាំទីផ្សារដែលបានបង្កើតឡើងដូចជា SAP, Oracle និង JD Edwards ដែលកម្មវិធីរបស់ពួកគេត្រូវបានរចនាឡើងដើម្បីសម្រេចបាននូវចុងបញ្ចប់ដូចគ្នាទៅនឹងសៀវភៅកត់ត្រាក្រដាស៖

- របាយការណ៍ប្រាក់ចំណូល

[25] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[26] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្ទៃកទី(ទំព័រទី២២-២៧),ឆ្នាំ២០២២(ទស្សនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣)

- តារាងតុល្យការ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់គោលបំណងសវនកម្ម និងអនុលោមភាព។

សព្វថ្ងៃនេះ អាជីវកម្មត្រូវបានខូចសម្រាប់ជម្រើសជាមួយនឹងកញ្ចប់គណនេយ្យដែលអាចរកបានភាគច្រើនត្រូវបានកែសម្រួលទៅតាមប្រជាសាស្ត្រ ឬឧស្សាហកម្មជាក់លាក់នៃអាជីវកម្ម។ ដូចអ្នកកាន់តំណែងមុនរបស់ពួកគេ ប្រព័ន្ធទាំងនេះខិតខំឆ្ពោះទៅរកការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលសមស្របនឹងតម្រូវការអនុលោមភាព ។

របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយប្រភេទដោយរៀបចំឡើងដោយផ្អែកទៅតាមវិធីសាស្ត្រគណនេយ្យដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយនៅពេលកំណត់ជាក់លាក់មួយ។របាយការណ៍ហិរញ្ញវត្ថុ គឺរាយការណ៍រាល់សកម្មភាពដែលទាក់ទងទៅនឹងការរប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ ហើយវាក៏បង្ហាញពីលទ្ធផលមួយ ដែលក្រុមហ៊ុនសម្រេចបាននូវក្នុងពេលវេលាជាក់លាក់ណាមួយ។ វាក៏ជាមធ្យោបាយមួយនៃការបញ្ជូននូវរូបភាពពិតនៃចំណេញ ខាត និងស្ថានភាពហិរញ្ញវត្ថុទៅកាន់អ្នកចាត់ចែងនិងអ្នកខាងក្រៅដែលមានចំណាប់អារម្មណ៍។ គេប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដើម្បីបង្ហាញពីគោលបំណង និងដំណើរការផ្សេងៗដែលកើតមានឡើងនៅក្នុងអង្គភាពហើយវា គឺជាឧបករណ៍មួយសម្រាប់វាស់ និងវាយតម្លៃលើដំណើរការនៃស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពសម្រាប់ធ្វើការព្យាករណ៍ និងការធ្វើផែនការយុទ្ធសាស្ត្ររបស់អង្គភាពសម្រាប់ពេលអនាគត់។ គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ គឺផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុការប្រើប្រាស់ព័ត៌មាន និងការប្រែប្រួលនៅស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយដែលមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ទូទៅក្នុងការធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។របាយការណ៍ហិរញ្ញវត្ថុនេះក៏បង្ហាញអំពីលទ្ធផលនៃការគ្រប់គ្រងធនធានរបស់អង្គភាពនៅក្នុងការិយបរិច្ឆេទមួយផងដែរ គឺផ្តល់ព័ត៌មានហិរញ្ញវត្ថុដែលមានប្រយោជន៍ដល់អ្នកវិនិយោគនិងការរកភាពមិនច្បាស់លាស់នៃចលនាសាច់ប្រាក់និងទង្វើផ្សេងៗរបស់អ្នកគ្រប់គ្រង[27]។

ដើម្បីសម្រេចបាននូវគោលបំណងទាំងនេះរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានផ្តល់នូវព័ត៌មានអំពីអង្គភាពដូចជា

- ទ្រព្យសកម្ម : Asset
- បំណុល : Laibilities
- មូលធន : Equity
- ចំណូលនិងចំណាយដែលរួមទាំងចំណេញនិងខាត : Revenues and Expenses including Profit and Loss
- ការប្រែប្រួលផ្នែកមូលធន : Other Charge in Equity
- លំហូរសាច់ប្រាក់ : Statement of Cash Flow។

**២.២.៣ តួនាទីនៃរបាយការណ៍ហិរញ្ញវត្ថុ**

តួនាទីចម្បងនៃរបាយការណ៍ហិញ្ញវត្ថុ គឺផ្តល់ព័ត៌មានហិរញ្ញវត្ថុអំពីក្រុមហ៊ុន។ វាអាចជួយអ្នកពាក់ព័ន្ធនិងអ្នកពាក់ព័ន្ធផ្សេងទៀតធ្វើការសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច រួមទាំងការអនុវត្តន៍កន្លងមក និងការវាយតម្លៃទីតាំងបច្ចុប្បន្ន ការព្យាករណ៍ និងការវិនិច្ឆ័យដំណើរការក្រុមហ៊ុន និងព្យាករណ៍ពីស្ថានភាពក្ស័យធន ឬការបរាជ័យណាមួយរបស់ក្រុមហ៊ុន។

[27] https://medium.com/overlayanalytics/the-history-of-financial-reporting-f952415a4a63( ទស្សនាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ )

គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុមានដូចជា៖

- ការអនុវត្តន៍កន្លងមក និងការវាយតម្លៃទីតាំងបច្ចុប្បន្ន
- ការព្យាករណ៍នៃប្រាក់ចំណូលសុទ្ធ និងការវិនិច្ឆ័យកំណើន
- ការព្យាករណ៍អំពីការក្ស័យធននៃអង្គភាពអាជីវកម្ម និងការបរាជ័យមួយផ្សេងទៀត
- ជួយភាគីពាក់ព័ន្ធ និងអ្នកប្រើប្រាស់ផ្សេងទៀតដើម្បីធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

ហេតុដូចនេះ របាយការណ៍ហិរញ្ញវត្ថុ គឺជាកត្តាសំខាន់ក្នុងការធានាថារូបភាពហិរញ្ញវត្ថុជាក់ស្តែងនៃអាជីវកម្មត្រូវបានបង្ហាញដល់អ្នកគ្រប់គ្រងនិងអ្នកពាក់ព័ន្ធខាងក្រៅ។វាបើកបង្ហួចសម្រាប់ការធ្វើការសម្រេចចិត្ត និងការធ្វើផែនការយុទ្ធសាស្ត្រដែរគេស្គាល់និងអប់រំអ្នកពាក់ព័ន្ធ។ របាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវជម្រុញឱ្យមានទំនុកចិត្តលើក្រុមហ៊ុន ហេតុនេះហើយការកសាងទំនុកចិត្តក៏ជាគោលបំណងសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុផងដែរ[28]។

## ២.៣ ផែនការនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

### ២.៣.១ និយមន័យនៃផែនការ

ការរៀបផែនការ គឺជាដំណើរការនៃការកំណត់គោលដៅអង្គភាព និងសម្រេចចិត្តនូវវិធីដែលល្អបំផុតដើម្បីសម្រេចគោលដៅទាំងនោះ។ ផែនការត្រូវបានបង្កើតឡើង ពីព្រោះបើគ្មានផែនការទេមិនអាចធ្វើអ្វីមួយឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលបានឡើយ (Efficiently and Effictivety)។ ហើយវាត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់នូវការតម្រែតម្រង់ទិស និងការកាត់បន្ថយភាពច្រំដែល កម្រិតគ្រោះថ្នាក់ថយចុះកាត់បន្ថយផែនការផ្លាស់ប្តូរភាពខ្ជះខ្ជាយអប្បបរមា កំណត់ស្តង់ដារដើម្បីសម្របសម្រួលក្នុងការត្រួតពិនិត្យ[29]។

### ២.៣.២ ប្រវត្តិនៃការរៀបចំផែនការ

នៅសហរដ្ឋអាមេរិច "ការធ្វើផែនការ"បានចាប់ផ្តើមលេចចេញជាអាជីព និងការអនុវត្តន៍តាមស្តង់ដារនៅដើមទសវត្សរ៍ឆ្នាំ ១៩០០។ ការកំណត់ពេលវេលាខាងក្រោមបង្ហាញពីការវិវឌ្ឍន៍នៃការធ្វើផែនការនៅ សហ-រដ្ឋអាមេរិច និងរបៀបដែលការអនុវត្តន៍បានជះឥទ្ធិពលនិងឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៅក្នុងសង្គមអាមេរិច។ ចំពោះអ្នករៀបចំផែនការទាំងនោះដែលចង់ឃើញពីវិសាលភាពនៃការបានធ្វើផែនការបានយ៉ាងធំធេង ហើយនេះមិនរាប់បញ្ចូលអ្នកធ្វើផែនការទាំងអស់។ នៅពេលដែលលោកប្រធានាធិបតី ហ្វ្រេនគ្លីនឌីរ៉ូសវេីត ត្រូវបានសម្ពោធនៅនាខែមីនា ឆ្នាំ១៩៣៣ អត្រាគ្មានការងារធ្វើស្ថិតនៅក្នុងជួរ ២៥ ភាគរយហើយតម្លៃសាច់ប្រាក់នៃទំនិញ និងសេវាកម្មដែលបានផលិតបានធ្លាក់ចុះជិតពាក់កណ្តាលចាប់តាំងពីឆ្នាំ១៩២៩។ ដំណើរការខុសប្រក្រតី និងមិនអាចភ្ជាប់កម្មករទំនេរជាមួយម៉ាស៊ីនទំនេរបានបង្កើតបរិយាយកាសបញ្ហាដែលអនុគ្រោះដល់ការធ្វើផែនការតាមរបៀបមួយដែលទសវត្សរ៍ឆ្នាំ១៩២០ មិនមាន។ ហើយវាអាចរាប់បញ្ចូលអ្វីៗទាំងអស់ចាប់ពីការគ្រប់គ្រងតូចតាចបំផុតលើការប្រើប្រាស់ដីធ្លីនៅក្នុងទីក្រុងតូចមួយ រហូតដល់ផែនការសេដ្ឋកិច្ចបែបកណ្តាលតាមបែបសូវៀត។ ប៉ុន្តែអ្នកនយោបាយ និងចលនាអាចជាបញ្ហាវាងវៃ។ ជាទូទៅភាពតានតឹងផ្នែកសេដ្ឋកិច្ច និងការស្រេងាកចិត្តនៃវិបត្តិសេដ្ឋកិច្ចមានទំនោរទៅរកការធ្វើផែនការ ច្រើនជាងអ្វីក៏ដោយដែលពាក្យនោះ អាចមានន័យ។ គាត់ជាអ្នកអនុវត្តន៍តាមនិយមន័យដែល និងកែសម្រួលប្រព័ន្ធតម្រូវការប៉ុន្តែគាត់មិនមានរបៀបវារៈ

[28] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៥-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

[29] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី១២-១៥,របស់និស្សិតឈ្មោះ ធុល ស្រីនីត

សម្រាប់ការតម្រែតម្រង់ទ្រង់ទ្រាយធំទេ។ អ្នកខ្លះនៅក្នុងរដ្ឋបាលរបស់គាត់ ដូចជាលេខាធិការក្រសួងមហាផ្ទៃ ហារ៉ូលអ៊ីកស៍ គឺជាអ្នកអភិរក្ស។ អ្នកផ្សេងទៀតដូចជា Rexford Tuwgell and Henry Wallace ដែលពូកែខាងឆ្វេងរបស់ Roosevelt បានពេញចិត្តនិងការផ្លាស់ប្តូរធំៗនិងការផ្លាស់ប្តូរអំណាចសេដ្ឋកិច្ចពីឯកជនទៅក្នុងដៃសាធារណៈ។ នៅក្នុងចរន្តនយោបាយ ដែលកំពុងការប៉ះទង្គិចនៃពេលវេលា ដែលបានកត់សម្គាល់មុនពេលក្រុមប្រឹក្សាភិបាលមិនបានធ្វើឱ្យមានការកត់សម្គាល់ច្រើននៅក្នុងប្រទេសនោះទេហើយនៅឆ្នាំ១៩៤៣ ត្រូវបានរំលាយដោយសភា។

ទោះយ៉ាងណាទំនាក់ទំនងថ្មីៗ របស់សហគមន៍គឺហ្គ្រីបបិលរដ្ឋ Maryland ភ្នំបៃតងរដ្ឋអូហៃអូ និង Greendale, Wisconsin ត្រូវបានសាងសង់។ គំនិតផ្តួចផ្តើម បានបង្កើតឡើងក្នុងឆ្នាំ១៩៣៣ ដើម្បីផ្តល់នូវវិធីសាស្ត្ររួមបញ្ចូលគ្នាទៅនិងទឹកជំនន់ការបង្កើតថាមពល និងការអភិរក្សធនធានធម្មជាតិ។ ទំនប់ដែលបានបំរើការសម្រាប់ការគ្រប់គ្រងទឹកជំនន់ក៏បានផលិតថាមពល ដែលសម្របសម្រួលអគ្គិសនីជនបទនាំឧស្សាហកម្មទៅក្នុងជ្រលងភ្នំ។ ការបង្កើតបឹងនៅពីក្រោមទំនប់វារីអគ្គិសនីនាំឱ្យទីភ្នាក់ងាររៀបចំផែនការកំសាន្ត។ នៅក្នុងចំណោមអ្នក ដែលពេញចិត្តនឹងតួនាទីកាន់តែធំសម្រាប់ការគ្រប់គ្រងរដ្ឋាភិបាល (TVA) Tennessee Valley Authority បានបង្ហាញពីភាពរីករាយជាគំរូសម្រាប់អ្វីដែលការធ្វើផែនការក្នុងទ្រង់ទ្រាយធំក្នុងតំបន់អាចសម្រេចបាន។

**២.៣.៣ វិធីសាស្ត្រក្នុងការធ្វើផែនការ**

ដំណើរការនៃការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុមានលក្ខណៈពីយ៉ាងដូចខាងក្រោមគឺៈ ផែនការនៃការធ្វើសវនកម្ម និងនីតិវិធីនៃការធ្វើសវនកម្ម។

ការរៀបចំផែនការនៃការធ្វើសវនកម្ម ឱ្យបានល្អនិងទាន់ពេលវេលា គឺមានសារៈសំខាន់បំផុតក្នុងការអនុវត្តន៍សវនកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តសិទ្ធភាព។ នៅក្នុងការរៀបចំផែនការដ៏ជាក់លាក់មួយត្រូវធ្វើការស្វែងយល់អំពីប្រភេទអាជីវកម្មកិច្ចប្រតិបត្តិការ និងបរិយាកាសរបស់អង្គភាពរងសវនកម្ម[30]។
ទៅលើនីតិវិធីក្នុងការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ គឺសវនករត្រូវធ្វើទៅលើនីតិវិធី ក្នុងចំណោមវិធីផ្សេងទៀត ដើម្បីរុករកហានិភ័យដែលកើតមានឡើងនៅក្នុងសហគ្រាសដែលរួមមាន ៥ យ៉ាងៈ

| | |
|---|---|
| ១. Business Acknowledge | : ការយល់ដឹងពីអាជីវកម្មរបស់អង្គភាព |
| ២. Test of Control | : វិធីសាស្ត្រឆែកឆេរទៅលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង |
| ៣. Test of Transaction | : វិធីសាស្ត្រឆែកឆេរលើកំណត់ត្រាគណនេយ្យ |
| ៤. Test of Balance | : វិធីសាស្ត្រឆែកឆេរលើសមតុល្យនៃរបាយការណ៍ហិរញ្ញវត្ថុ |
| ៥. Analytical Procedure | : នីតិវិធីវិភាគ។ |

[30] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្ទៃកទីរ( ទំព័រទី២២-២៧ ),ឆ្នាំ២០២២( ទស្សនាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ )

1.ICS (Internal Control System) ?
2.Understanding the ICS of an Entity
សិក្សាយល់ដឹងពីICSរបស់អង្គភាពណា១- ដែលសវនករបម្រុងនឹងចុះឆែក។
3.TOC វិធីសាស្ត្រស្ទាក់ចាប់Riskក្នុងICS

**Planning:M ⟹ AR**

| | |
|---|---|
| **AR** | **Audit Test** |
| **IR** | **I. Test of Control** |
| x | 1.Business Acknowledge |
| **CR** | 2.Test of Control → 3.TOC |
| x | **II. Substantive Test** |
| **DR** | 3.Test of Transaction |
| | 4.Test of Balance |
| | 5.Analytical Procedure |

ការរៀបចំផែនការសវនកម្ម គឺមានសារៈសំខាន់ណាស់ក្នុងការអនុវត្តន៍ការងារសវនកម្មមួយ និងធ្វើឱ្យមានប្រសិទ្ធភាព។ ដូចនេះ សវនករចាំបាច់ត្រូវតែរៀបចំផែនការឱ្យបានគ្រប់គ្រាន់ ហើយបើក្នុងករណីចាំបាច់ត្រូវរកជំនួយការ[31]។

ផែនការទាំងនោះទាក់ទងនឹងការកំណត់នូវ៖

- Nature (Type of Test)
  - Test of Control
  - Substantive Test
  - Dual Purpose Test
- Timing
  - កំណត់ឱ្យប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃ
  - ចាប់ផ្តើមពេលណា
  - Extend (Scope or Size)
  - គឺនិយាយពីការជ្រើសរើសទំហំនៃ Substantive Test ថាតើយើងគួររើសយកមួយណារវាង Extensive Substantive Test និង Restricted Substantive Test។

ការរៀបចំផែនការ គឺត្រូវវិភាគកត្តាមួយចំនួនទៀតដូចខាងក្រោម៖

- Inherent Risk
- Anticipated Reliance on Internal Control
- Preliminary Judgment about Materiality
- The Type of Audit Report

ការរៀបចំរបាយការណ៍សវនកម្ម និងត្រូវបានធ្វើឡើងបន្ទាប់ពីបានធ្វើសវនកម្មចប់សព្វគ្រប់ហើយដែលជាតួនាទីរបស់ប្រធានក្រុមសវនករ។ ប្រធានក្រុមសវនករ ត្រូវប្រមូលព័ត៌មានពីសវនករនានាដែលបានកត់ត្រាចូលក្នុងក្រដាសលឿងពេលធ្វើសវនកម្ម ដើម្បីធ្វើការសន្និដ្ឋាន និងវាយតម្លៃទៅលើរបាយការណ៍ហិរញ្ញវត្ថុ វាយតម្លៃលើប្រព័ន្ធនៃការគ្រប់គ្រង និងរៀបចំ ដើម្បីចេញរបាយការណ៍សវនកម្មលើការធ្វើសវនកម្មលើធនាគារ ឬក្រុមហ៊ុន។ កាលបរិច្ឆេទក្នុងការចេញរបាយការណ៍សវនកម្ម គឺអាស្រ័យទៅលើកិច្ចព្រមព្រៀងនៅក្នុងការបានរៀបចំនាពេលកន្លងមក។ សវនករត្រូវធានាឱ្យបានថា របាយការណ៍សវនកម្មរបស់ខ្លួននឹងត្រូវចប់សព្វគ្រប់ ហើយបញ្ជូនទៅឱ្យអតិថិជនរបស់ខ្លួនតាមកិច្ចសន្យា។

[31] វិទ្យាស្ថាន វ៉ាន់ដា,សវនកម្មផ្នែកទី(ទំព័រទី២២-២៧),ឆ្នាំ២០២២(ទស្សនាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣)

សវនករអាចប្រើបច្ចេកទេសផ្សេងៗជាច្រើនដើម្បីសម្រេចថា តើពួកគេគួរដាក់ការជឿទុកចិត្តលើការធ្វើសវនកម្ម លើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ហើយនិង Substantive Test ប៉ុន្មាន ក្នុងការប្រមូលភស្តុតាង។ ដូចនេះ សវនករត្រូវស្គាល់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងទាំងនោះវាប៉ះពាល់យ៉ាងណា Substantive Test? ចំពោះសមតុល្យនៃគណនីនិងការអះអាងទាក់ទងនឹងសវនករពេលសវនកម្មប្រហែលប្រើយុទ្ធសាស្ត្រដោយដាក់ការជឿទុកចិត្តលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និង Substantive Test ក្នុងការប្រមូលទិន្នន័យដើម្បីប្រើប្រាស់ពេលវេលាឱ្យកាន់តែមានប្រសិទ្ធភាព។ វិធីសាស្ត្រក្នុងការធ្វើផែនការមាន២គឺ៖

- វិធីសាស្ត្រពីលើទៅក្រោម៖ អ្នកគ្រប់គ្រងថ្នាក់កំពូល កំណត់គោលដៅរួម និងបន្ទាប់មកអនុញ្ញាតអ្នកថ្នាក់ទាបបង្កើតផែនការនៅក្នុងលក្ខខណ្ឌទាំងនោះ។
- វិធីសាស្ត្រពីក្រោមឡើងលើ៖ គឺជាផែនការត្រូវបានគ្រោងបង្កើតអ្នកគ្រប់គ្រងថ្នាក់ទាបដោយគ្មានលក្ខខណ្ឌច្រើនហើយបន្ទាប់មកបញ្ជូនជាបន្តបន្ទាប់ដាក់ឆ្លងតាមឋានានុក្រមទៅកាន់អ្នកគ្រប់គ្រងថ្នាក់ខ្ពស់។

មធ្យោបាយក្នុងការធ្វើផែនការមាន៥ដូចជា៖

- ថវិកា : Budgets
- តារាងសកម្មភាព : Action Plan
- គំរូ : Standard
- គោលនយោបាយ : Policy
- ទម្រង់បែបបទ : Procedure។

រយៈពេលក្នុងការធ្វើផែនការមាន៣ដូចជា៖

- ផែនការរយៈពេលខ្លី : Short-Term Planning (S.T.P)
- ផែនការរយៈពេលមធ្យម : Medium-Term Planning (M.T.P)
- ផែនការរយៈពេលវែង : Long-Term Planning (L.T.P)។

ដំណាក់កាលនៃការកសាងផែនការយុទ្ធសាស្ត្រមាន៩ដូចខាងក្រោម៖

- ការរៀបចំគោលដៅ
- កំណត់ច្បាស់នូវទិសដៅ និងយុទ្ធសាស្ត្របច្ចុប្បន្ន
- ការវិភាគមជ្ឈដ្ឋាន
- វិភាគធនធានមនុស្ស
- ការកំណត់ឱកាស និងការគំរាមគំហែង
- កំណត់ទំហំប្រែប្រួលជាយុទ្ធសាស្ត្រ
- ការធ្វើសេចក្តីសម្រេចជាយុទ្ធសាស្ត្រ
- ការអនុវត្តន៍យុទ្ធសាស្ត្រ
- ការត្រួតពិនិត្យមើលដំណើរការ[32]។

[32] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី១២-១៥,របស់និស្សិតឈ្មោះ ធុល ស្រីនីត

## ២.៤ ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

### ២.៤.១ និយមន័យនៃធនាគារ

ធនាគារ គឺជាស្ថាប័ន ឬគ្រឹះស្ថានសម្រាប់ទទួលប្រាក់បញ្ញើ ឬបណ្ដាក់ទុនជាបណ្ដាញប្រមូលប្រាក់សន្សំដែលឥតប្រើប្រាស់ ឬនៅទំនេរក្នុងសេដ្ឋកិច្ចយកទៅចែកចាយនៅតាមគ្រប់វិស័យសេដ្ឋកិច្ចតាមការផ្ដល់ឥណទាន ដើម្បីជួយលើកស្ទួយសកម្មភាព និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម[33]។

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការផ្ដល់សេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទដូចជាទទួលប្រាក់បញ្ញើរដែលគ្មានមុខសញ្ញាប្រើប្រាស់ និងប្រាក់សន្សំពីសាធារណជន ផ្ដល់ឥណទានឱ្យសាធារណៈជន និងអាជីវកម្ម ផ្ដល់ឥណទានដល់អាជីវកម្មឯកជន ដើម្បីធ្វើការវិនិយោគក្រោមរូបភាព សញ្ញាប័ណ្ណ និងមូលបត្រមានតម្លៃ ដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ម្ចាស់ក្រុមហ៊ុន[34]។

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុមួយ ដែលទទួលប្រាក់បញ្ញើ ដើម្បីដកតាមតម្រូវការ ដូចជាការសរសេរមូលប្បទានបត្រ ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិចហើយនឹងផ្ដល់ឥណទានទៅឱ្យសាធារណៈជននិងអាជីវកម្ម ផ្ដល់ឥណទានដល់អាជីវកម្មឯកជន ដើម្បីពង្រីកសន្និធិរបស់ទំនិញនៅក្នុងអាជីវកម្មរបស់ពួកគេ ឬដើម្បីទិញសម្ភារៈបរិក្ខាថ្មីៗ[35]។

### ២.៤.២ ប្រវត្តិនៃធនាគារ

ធនាគារបានកើតឡើងក្នុងទម្រង់មួយនៃប្រវត្តិសាស្ត្រដែលបានកត់ត្រា ជាអ្នកចេញរូបិយប័ណ្ណ និងឃ្លាំងទ្រព្យសម្បត្តិ។ សូម្បីតែមុនពេលរូបិយប័ណ្ណលេចឡើង ដោយបានចាប់ផ្ដើមជាមួយនឹងកាក់ដំបូង ហើយបន្ទាប់មកបន្ថែមអ្វីដែលត្រូវគេទទួលស្គាល់ថាជាក្រដាសប្រាក់ ដើម្បីគ្រប់គ្រងការប្រមូលផ្ដុំទ្រព្យសម្បត្តិ។ នៅពេលដែលរូបិយប័ណ្ណបានលេចចេញ វាបានធ្វើឱ្យការផ្លាស់ប្ដូរតម្លៃនេះកាន់តែងាយស្រួល និងមានប្រសិទ្ធិភាព ហើយឥឡូវនេះ គេអាចធ្វើអាជីវកម្មបានយ៉ាងសាមញ្ញដូចជាកាក់ ឬមាស សម្រាប់ទំនិញផ្សេងទៀត។ អ្នកមិនអាចមានទម្រង់រូបិយប័ណ្ណដោយគ្មានធនាគារគ្រប់គ្រងវានោះទេ ហើយសូម្បីតែការចេញក៏ទាមទារការគ្រប់គ្រងធនាគារប្រភេទខ្លះដែរ[36]។

ដូចនេះ ការចាប់កំណើតដំបូងរបស់ធនាគារ គឺជាធនាគារកណ្ដាល ដែលដំណើរការដោយរដ្ឋាភិបាល ដើម្បីជួយគ្រប់គ្រងសេដ្ឋកិច្ចរបស់ពួកគេ ទោះបីជានៅពេលដែលមនុស្សភាគច្រើនគិតពីធនាគារ ពួកគេតែងតែគិតថាធនាគារលក់រាយ កន្លែងដែលពួកគេដាក់ប្រាក់របស់ពួកគេ និងខ្ចីប្រាក់ពីពួកគេ។ នៅពេលដែលធនាគារមានការអភិវឌ្ឍន៍ តម្រូវការបានកើនឡើងសម្រាប់ប្រជាជនដែលផ្ដល់សេវាដោយធនាគារនៅកម្រិតលក់រាយ។ ពេលដែលមនុស្សប្រមូលទ្រព្យសម្បត្តិក្នុងទម្រង់ជារូបិយប័ណ្ណ លុយត្រូវបានរក្សាទុកនៅកន្លែងណាមួយ ហើយការជ្រើសរើសផ្ទះមិនមែនជាកន្លែងដ៏ល្អសម្រាប់កិច្ចការនេះទេ ជាពិសេសប្រសិនបើមនុស្សម្នាក់បានប្រមូលប្រាក់ជាច្រើន។ ឥឡូវនេះ ធនាគារក៏មានការវិវត្តន៍បង្កើតជាប្រព័ន្ធធនាគារដូចដែលបានដឹងដូចសព្វថ្ងៃនេះ។

[33] https://www.hemsarith.wordpress.com( ទស្សនាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ )

[34] https://www.hemsarith.wordpress.com( ទស្សនាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ )

[35] https://www.academia.edu( ទស្សនាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ )

[36] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៤-៨,របស់និស្សិតឈ្មោះ សេង ស៊ូណា

### ២.៤.៣ តួនាទីរបស់ធនាគារ

ធនាគារ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុ ដែលពាក់ព័ន្ធការខ្ចីប្រាក់ និងការផ្តល់ប្រាក់កម្ចី។ ធនាគារយកប្រាក់បញ្ញើរបស់អតិថិជនជាថ្នូរនិងការបង់ប្រាក់ឱ្យអតិថិជននូវការប្រាក់ប្រចាំឆ្នាំ។ បន្ទាប់មក ធនាគារប្រើប្រាស់ប្រាក់បញ្ញើជាច្រើនទាំងនេះ ដើម្បីផ្តល់ប្រាក់កម្ចីដល់អតិថិជនផ្សេងទៀតសម្រាប់កម្ចីផ្សេងៗ។ ភាពខុសគ្នារវាងប្រាក់ទាំងពីរគឺប្រសិទ្ធិភាពលើប្រាក់ចំណេញសម្រាប់ធនាគារ[37]។

គោលបំណងសំខាន់របស់ធនាគារៈ

- រក្សាលុយឱ្យមានប្រសិទ្ធភាពសម្រាប់អតិថិជន
- ផ្តល់កម្ចីដល់ក្រុមហ៊ុន អតិថិជន និងអ្នកទិញអចលនទ្រព្យ
- ផ្តល់ជូនអតិថិជននូវការប្រាក់លើប្រាក់បញ្ញើ និងជួយការពារអតិផរណា
- ផ្តលប្រឹក្សាផ្នែកហិរញ្ញវត្ថុ និងសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធជាដើម។

ធនាគារអនុវត្តន៍មុខងារចម្បងពីរយ៉ាងៈ

- ការទទួលប្រាក់បញ្ញើៈ មានប្រាក់បញ្ញើសន្សំ ប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើបច្ចុប្បន្ន និងប្រាក់បញ្ញើបន្តបន្ទាប់គ្នា ។
- មុខងារផ្តល់ប្រាក់កម្ចី និងបុរេប្រទានៈ មានប្រាក់កម្ចី ឥណទានសាច់ប្រាក់ បញ្ចុះតម្លៃវិក័យប័ត្រប្តូរប្រាក់ និង Bank Overdraft។

តួនាទីសំខាន់របស់ធនាគាររួមមានៈ

- ធនាគារសន្សំប្រាក់ប្រកបដោយសុវត្ថិភាពខ្ពស់
- ធនាគារសន្សំប្រាក់របស់អ្នកជាបន្តបន្ទាប់
- ធនាគារផ្គត់ផ្គង់ប្រាក់ចាំបាច់សម្រាប់ប្រភេទអាជីវកម្ម និងស្ថាប័នផ្សេងៗ
- ធនាគារផ្ទេរប្រាក់របស់អតិថិជនពីកន្លែងមួយទៅកន្លែងមួយទៀត
- ធនាគារបង្កើតមធ្យោបាយនៃការផ្លាស់ប្តូរ
- សេវាធនាគារតាមអ៊ីនធើណិត
- Mobile Banking
- ការផ្តល់ឱកាសឥណទានសម្រាប់កិច្ចសហប្រតិបត្តិការ និងបុគ្គល
- ជួយសម្រួលដល់លំហូរនៃមូលនិធិនៅក្នុងសេដ្ឋកិច្ច
- ធានាថាធនធានហិរញ្ញវត្ថុត្រូវបានបែងចែកដោយប្រសិទ្ធិភាពឆ្ពោះទៅរកកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍
- ធនាគារត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពជីវិតប្រចាំថ្ងៃរបស់យើង ដូចជាការបើកប្រាក់បៀវត្សរ៍ការដកប្រាក់ និងការសន្សំជាដើម។

[37] វិទ្យាស្ថាន វ៉ាន់ដា,របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី១២-១៥,របស់និស្សិតឈ្មោះ ធុល ស្រីនីត

# ជំពូកទី៣
# ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២របស់ ធនាគារ វីង (ខេមបូឌា) ម.ក ស្នាក់ការកណ្តាល

## ៣.១ ស្ថានភាពទូទៅរបស់ធនាគារវីង(ខេមបូឌា)ម.ក

### ៣.១.១ ប្រវត្តិរបស់ធនាគារវីង

ធនាគារ វីង ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០០៨ ជាក្រុមហ៊ុនឯកជនមានកម្រិតក្រោមការចុះបញ្ជីលេខ 00005108 ។ ធនាគារបានផ្ទេរពីធនាគារឯកទេស ទៅជាធនាគារពាណិជ្ជ និងទទួលបានអាជ្ញាប័ណ្ណធនាគារពាណិជ្ជពី ធនាគារជាតិនៃកម្ពុជា សម្រាប់រយៈពេលមិនកំណត់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០។ ក្នុងឆ្នាំបន្ទាប់ធនាគារបានធ្វើបច្ចុប្បន្នភាពលើលក្ខន្តិកៈក្រុមហ៊ុន ពី ធនាគារឯកទេសវីង (ខេមបូឌា) លីមីធីត ទៅជា ធនាគារ វីង (ខេមបូឌា) ម.ក ហើយត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម(MOC) នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១។សកម្មភាពចម្បងរបស់ធនាគាររួមមានការផ្តល់សេវាទូទាត់តាមរយៈប្រព័ន្ធអេឡិចត្រូនិក ការទូទាត់តាមទូរស័ព្ទ ការធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។
ទីស្នាក់ការចុះបញ្ជីនៃធនាគារ មានទីតាំងនៅ អគារ ៧២១ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា[38]។

ធនាគារ វីង ជាធនាគារសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបត្រូវបានជំរុញដោយចក្ខុវិស័យដើម្បីផ្តល់ជូនប្រជាជនកម្ពុជាគ្រប់រូបនូវភាពងាយស្រួលក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុដែលចាំបាច់ និងធ្វើឱ្យប្រសើរឡើងនូវការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ចាប់តាំងត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៨ មក ធនាគារ វីងមានការរីកចម្រើនយ៉ាងឆាប់រហ័សហើយបានជួយអភិវឌ្ឍន៍ជីវិតរស់នៅរបស់ប្រជាជនកម្ពុជា បានតាមរយៈការផ្តល់សេវាកម្មទូទាត់ចល័តនៅទូទាំងប្រទេស។ សមិទ្ធផលទាំងអស់នេះធ្វើឱ្យ ធនាគារវីង ទទួលបានការជឿទុកចិត្តពីសហគមន៍។ ធនាគារបានអភិវឌ្ឍន៍ខ្លួនពីអ្នកដំណើរដោយតតីយភាគីទៅជាធនាគារឯកទេសក្នុងឆ្នាំ ២០១៤ ហើយកាលពីពេលថ្មីៗនេះ ត្រូវបានក្លាយទៅជាធនាគារពាណិជ្ជ។ ទោះបីមានបញ្ហាប្រឈមនានាក្តី ធនាគារវីងបានបង្ហាញឱ្យឃើញនូវឆន្ទៈ ក្នុងការផ្តល់សេវាកម្មប្រកបដោយងាយស្រួលដល់អតិថិជនរបស់ខ្លួន។ អាជ្ញាប័ណ្ណធនាគារពាណិជ្ជ ដែលផ្តល់ជូនដោយធនាគារជាតិនៃកម្ពុជាកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រោមឈ្មោះជាធនាគារ វីង (ខេមបូឌា) ម.ក អនុញ្ញាតឱ្យធនាគារវីងពង្រីកសេវាកម្មធនាគារពេញលេញនៅគ្រប់ទិសទីក្នុងប្រទេសកម្ពុជា។ ធនាគារ វីង បានអភិវឌ្ឍន៍ដោយចាប់ផ្តើមពីប្រតិបត្តិការតូចរហូតដល់ប្រតិបត្តិការទ្រង់ទ្រាយធំតាមរយៈការផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទ ដើម្បីជួយលើកកម្ពស់ជីវិតរស់នៅរបស់ប្រជាជនកម្ពុជា។ ក្រោយពេលដាក់សម្ពោធជាធនាគារពាណិជ្ជតាមប្រព័ន្ធអនឡាញពីឆ្នាំ ២០២១ ធនាគារវីងបានចាប់ផ្តើមផ្តល់ផលិតផលហិរញ្ញវត្ថុទំនើបៗជាច្រើន សម្រាប់អតិថិជនជារូបវន្តបុគ្គល និងសាជីវកម្មនានា។ ផលិតផលទាំងនោះរួមមានដូចជា សេវាប្រាក់កម្ចី សេវាប្រាក់បញ្ញើរ សេវាសន្សំខ្នាតតូច សេវាណែនាំឥណទានសេវាផ្ទេរប្រាក់ ការទូទាត់ទឹកភ្លើង និងធានារ៉ាប់រង សេវាទូទាត់ចង្វាក់ផ្គត់ផ្គង់ សេវាប្រាក់បៀវត្ស និងការបញ្ចូល

[38] https://www.wingbank.com.kh/km/about-wing/annual-report/( ទស្សនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣)

ទឹកប្រាក់ទូរស័ព្ទ។ លើសពីនេះធនាគារវីងផ្តល់ជូនសេវាទូទាត់តាមរយៈ“Wingpay”ផងដែរ។សព្វថ្ងៃធនាគារវីងបម្រើប្រជាជនកម្ពុជាទូទាំងប្រទេសដោយគ្របដណ្តប់ ១០០ ភាគរយនៃស្រុកនានាក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីវីងប៉ែងអេបដែលប្រកបដោយភាពច្នៃប្រឌិតថ្មីៗ។ ប្រតិបត្តិការនេះអាចធ្វើទៅបាន តាមរយៈការសហការជាមួយក្រុមហ៊ុនយក្សជាច្រើនក្នុងឧស្សាហកម្មដូចជា៖ Mastercard, MoneyGram, AliPay, Western Union, Visa និងRia ជាដើម។ តាមរយៈកម្មវិធីវីងប៉ែងអេបធនាគារវីងផ្តល់ជូនដំណោះស្រាយបែបបច្ចេកវិទ្យាឌីជីថលជាង ១០០ ប្រភេទដើម្បីដោះស្រាយបញ្ហាជាក់លាក់នានាឱ្យពលរដ្ឋកម្ពុជាគ្រប់គ្នា។ ១៣ លាននាក់ តាមរយៈប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុរបស់ខ្លួន។ បច្ចុប្បន្ននេះមានក្រុមហ៊ុនជាង ៥០០ និងទីភ្នាក់ងាររដ្ឋាភិបាល ចំនួន ១០ កំពុងប្រើប្រាស់សេវាកម្មបើកប្រាក់បៀវត្សន៍និងសេវាទូទាត់ប្រាក់របស់ធនាគារវីង ដែលជួយពន្លឿនការទូទាត់ និងប្រតិបត្តិការអាជីវកម្ម។ មានអាជីវកម្មដៃគូជាង ៨០,០០០ ទីតាំងរួមមាន៖ ភោជនីយដ្ឋាន ហាងទំនិញ សាឡន ហាងកេសជ្ជៈ ហាងលក់សម្លៀកបំពាក់ និងអាជីវកម្មជាច្រើនផ្សេងទៀត កំពុងប្រើប្រាស់សេវាកម្មទូទាត់របស់ធនាគារវីងដែលប្រកបដោយសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ធនាគារវីងផ្តល់អាទិ្ទភាពខ្ពស់លើកិច្ចការសមាគមន៍ ហើយបានអនុវត្តន៍កម្មវិធីទំនួលខុសត្រូវសង្គមជាច្រើន។ ជាលទ្ធផល ក្នុងឆ្នាំ២០២១ ធនាគារវីង បានឈ្នះពានរង្វាន់ “AmCham Cambodia 2021 CSR Excellence Award” តាមរយៈសកម្មភាពឥទ្ធិពលប្រកបដោយអត្ថន័យ និងមានសារៈសំខាន់បាននៅលើជីវិតរស់នៅរបស់ប្រជាជនដែលជួបការលំបាកទាំងផ្នែកហិរញ្ញវត្ថុ និងបញ្ហាផ្សេងៗទៀត។ ធនាគារវីងប្តេជ្ញា ផ្តល់នូវបរិយាបទហិរញ្ញវត្ថុ យេនឌ័រ តាមបែបបច្ចេកវិទ្យាឌីជីថល។ ហើយយធនាគារនេះផ្តល់អាទិ្ទភាពខ្ពស់ ដល់ការផ្តល់សេវាហិរញ្ញវត្ថុដល់អ្នកមិនមានគណនីធនាគារ និងមិនស្ថិតក្នុងបណ្តាញធនាគារដែលអនុញ្ញាតឱ្យប្រជាជន គ្រប់រូបទទួលបាននូវភាពងាយស្រួល និងសុវត្ថិភាពពីសេវាកម្មហិរញ្ញវត្ថុដែលមានភាពទំនើបទាន់សម័យ។

ធនាគារ វីង ជាអ្នកផ្តល់សេវាកម្មធនាគារតាមទូរស័ព្ទដៃដំបូងគេនៅកម្ពុជាដែលមានការប្តេជ្ញាចិត្តនៅក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុទៅដល់អ្នកដែលមិនមានគណនីធនាគារ។ ធនាគារវីងក៏ជាធនាគារឯកទេសមួយក្នុងចំណោមធនាគារឯកទេសដែលផ្តល់សេវាកម្មធនាគារ បានតាមរយៈទូរស័ព្ទដៃដែលមានតិចតួចបំផុតរបស់ពិភពលោក។ ចាប់ផ្តើមនៅឆ្នាំ ២០០៩ ធនាគារវីងបានផ្តល់មធ្យោបាយផ្ញើរ និងទទួលប្រាក់គ្រប់ពេលវេលាគ្រប់ទីកន្លែងទៅដល់ប្រជាជនកម្ពុជាតាមការប្រើប្រាស់ទូរស័ព្ទដៃ។ ផលិតផលនិងសេវាកម្មវីង ផ្តល់ឱ្យប្រជាជនកម្ពុជាគ្រប់រូបអាចប្រើប្រាស់សេវាកម្មផ្សេងៗជាច្រើនដូចជាប្តូរប្រាក់ក្នុងស្រុកបញ្ចូលលុយទូរស័ព្ទ បង់វិក្កយបត្រវីងគិតលុយ និងការទូទាត់ប្រាក់តាម អ៊ិនធិណេត។ វីងនៅរក្សាតំណែងជាអ្នកផ្តល់សេវាកម្មធនាគារតាមទូរស័ព្ទដែលឈានមុខគេនៅកម្ពុជាដែលមានបណ្តាញភ្នាក់ងារ វីងខាល អ៊ិចប្រេសគ្របដណ្តប់គ្រប់ស្រុកទូទាំងប្រទេស។ ជាមួយវីង អ្នកដែលធ្វើការនៅទីប្រជុំជន ឬ ឆ្ងាយពីផ្ទះលែងព្រួយបារម្ភពីការផ្ញើរប្រាក់ដែលពួកគេខំរកយ៉ាងលំបាកទៅកាន់ក្រុមគ្រួសារទៀតហើយ។ វីងផ្តល់សេវាកម្មដែល ងាយស្រួល រហ័ស និងមានសុវត្ថិភាពដោយមិនចាំបាច់ធ្វើដំណើរឆ្ងាយទៅបង់វិក្កបត្រទឹកភ្លើង និងវិក្កបត្រផ្សេងៗ ឬបញ្ចូលលុយទូរស័ព្ទ ដោយគេអាចធ្វើប្រតិបត្តិការទាំងនេះតាមរយៈទូរស័ព្ទដៃរបស់ពួកគេ ឬភ្នាកងារវីងណាមួយក៏បាន។ វីងក៏ផ្តល់ដំណោះស្រាយនៅក្នុងការប្រមូលសាច់ប្រាក់ទៅដល់ក្រុមហ៊ុនផ្សេងៗ តាមរយៈសេវាកម្មសហគ្រាសរបស់ខ្លួន។ ជាមួយវីងសហគ្រាសទាំងតូចឬធំ អាចប្រើប្រាស់សេវាកម្មប្រមូលសាច់ប្រាក់និងបើកប្រាក់បៀវត្សន៍ទៅកាន់បុគ្គលិករបស់

ខ្លួនបានយ៉ាងស្រួល។ តាមរយៈសេវាកម្មនេះធនាគារវីងមិនត្រឹមតែផ្តល់សេវាកម្មធនាគារងាយស្រួលដល់អតិថិ- ជនប៉ុណ្ណោះទេ ថែមទាំងជួយនៅក្នុងការរីកចម្រើនរបស់សហគ្រាសតូច ធំ និងវិស័យឧស្សាហកម្មនៅ កម្ពុជា ដែលជួយឱ្យមាន ប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់ប្រាក់។ វីងបានអនុវត្តន៍ពេញលេញទៅតាមស្តង់ដារធនាគារ អន្តរជាតិ ទាំងការយកចិត្តទុកដាក់ស្គាល់អតិថិជនតាមរយៈឯកសារសម្គាល់ខ្លួនការប្រឆាំងហិរញ្ញប្បទានភេរ- វកម្ម និងការប្រឆាំងការលាងលុយ។

**៣.១.២ ទស្សនវិស័យ ឬបេសកកម្ម**

**ទស្សនវិស័យ** ៖ ផ្តល់នូវភាពងាយស្រួល និងការទទួលបានដំណោះស្រាយហិរញ្ញវត្ថុឌីជីថល ទៅដល់ប្រជាជនកម្ពុជា ដើម្បីធ្វើឱ្យជីវភាពប្រចាំថ្ងៃរបស់ពួកគេប្រសើរ។

**បេសកកម្ម** ៖ អតិថិជនជាអាទិភាព ស្វែងយល់ពីតម្រូវការទីផ្សារដោយការផ្តល់ជូននូវផលិតផល និងសេវាកម្មដែលល្អបំផុតដើម្បីបំពេញតម្រូវការអតិថិជនទាន់ពេលវេលា។ បុគ្គលិកជាសសរស្តម្ភ បង្កើតឱ្យមានបរិយាកាសការងារល្អដែលមានការទទួលស្គាល់នូវស្នាដៃនិងសមិទ្ធិផលការងារល្អជាមួយ និងការអនុវត្តន៍គុណតំលៃរបស់ធនាគារ។ ផ្តោតលើការអភិវឌ្ឍសហគមន៍ ផ្តល់ជូននូវសេវាហិរញ្ញវត្ថុចល័តដែលងាយស្រួល និងអាចទទួលយកបានសម្រាប់ជួយសហគមន៍ឱ្យមានជីវភាពប្រសើរឡើងនិងកាត់បន្ថយវិសមភាពសង្គមផងដែរ។ សមិទ្ធិផលខ្ពស់សម្រាប់ភាគទុនិក បង្កើតនូវស្តង់ដារអភិបាលកិច្ចល្អមួយដែលរក្សាឱ្យបាននូវអត្ថប្រយោជន៍ខ្ពស់សម្រាប់ភាគទុនិកក្នុងគោលដៅអាជីវកម្មរយៈពេលខ្លីនិងរយៈពេលវែងជាមួយការឈានមុខគេជាធនាគារដែលផ្តល់សេវាកម្មហិរញ្ញវត្ថុចល័ត ដែលងាយស្រួលបំផុតសម្រាប់អតិថិជនគ្រប់រូប។

**៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង**

**ក. ក្រុមប្រឹក្សាភិបាល**

អង្គការគ្រប់គ្រងធនាគារ គឺជាក្រុមប្រឹក្សាភិបាល ដែលតទៅហៅថា ក្រុមប្រឹក្សាភិបាល ឬ (BOD) Board of Director។ ក្រុមប្រឹក្សាភិបាល ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន ៥រូប ដែលរួមមាន ប្រធានអភិបាល និងអភិបាលចំនួន ៣រូប និងអភិបាលឯករាជ្យចំនួន ២រូប។ ក្រុមប្រឹក្សាភិបាល បានបង្កើតយន្តការណ៍បន្តបន្ទាប់សម្រាប់ការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យធំៗ ដែលធនាគារវីង ជួបប្រទះហើយដំណើរការនេះ រួមមានការពង្រឹង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង នៅពេលដែលមានការផ្លាស់ប្តូរ បរិយាកាសអាជីវកម្ម ឬគោលការណ៍ណែនាំ ផ្នែកនិយ័តករ។

**ខ. គណៈកម្មាធិការសវនកម្ម និងហានិភ័យ**

បន្ទាប់ពីក្រុមប្រឹក្សាភិបាល មានគណៈកម្មាធិការសវនកម្ម និងហានិភ័យ ដែលមានសមាសភាពមកពីសមាជិកក្រុមប្រឹក្សាភិបាល។ ក្នុងនាមជាអនុប្រធានក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនេះមានតួនាទីត្រួតពិនិត្យមើលទិសដៅរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងហានិភ័យ និងគោលនយោបាយថ្នាក់ខ្ពស់ព្រមទាំងគ្រប់គ្រងលើបញ្ហាសវនកម្មខាងក្នុង និងខាងក្រៅផងដែរ[39]។

[39] https://www.wingbank.com.kh/km/about-wing/annual-report/( ទស្សនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ )

### គ. គណៈគ្រប់គ្រង

ធនាគារវីង នៅក្រុមការត្រួតពិនិត្យតាមដានរបស់គណៈគ្រប់គ្រង នៅក្នុងគណៈគ្រប់គ្រងនេះមានសមាសភាព ១០រូប ដែលដឹកនាំដោយអគ្គនាយក ៣រូប និងនាយក ៧រូបទៀតជាសមាជិក និងប្រធានផ្នែក ៩ រូបផងដែរ។ នាយកទាំង ៧រូប មានភារៈកិច្ចគ្រប់គ្រង និងដឹកនាំខុសៗគ្នាទៅតាមនាយកដ្ឋាននីមួយៗគឺៈ

1. នាយកប្រតិបត្តិ មាន ៧ផ្នែកគឺៈ
   - នាយកប្រតិបត្តិតាម
   - នាយកគ្រប់គ្រងព័ត៌មានវិទ្យា
   - នាយកគ្រប់គ្រងអាជីវកម្ម
   - នាយកផ្នែកហិរញ្ញវត្ថុ
   - នាយកផ្នែកប័ណ្ណ និងអាជីវកម្មទូទាត់
   - នាយកគ្រប់គ្រងឥណទាន
   - នាយកផ្នែកសវនកម្មផ្ទៃក្នុង។
2. ប្រធានផ្នែកសេវាកម្ម មាន ៩ផ្នែកគឺៈ
   - ប្រធានផ្នែកសវនកម្ម
   - ប្រធានផ្នែកហានិភ័យប្រតិបត្តិការ
   - ប្រធានផ្នែកប្រតិបត្តិការធនាគារ
   - ប្រធានផ្នែកសេវាអតិថិជន
   - ប្រធានផ្នែកវិភាគអជីវកម្ម
   - ប្រធានផ្នែកម៉ាក់ និងស្លាកយីហោ
   - ប្រធានផ្នែកគម្រោង
   - ប្រធានផ្នែកធនធានមនុស្ស
   - ប្រធានផ្នែកអចលនទ្រព្យ[40]។

## ៣.២ សមាសធាតុរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវីង

សមាសជាតុនៃរបាយការណ៍ហិរញ្ញវត្ថុ ជាទូទៅសមាសជាតុនៃរបាយការណ៍ហិរញ្ញវត្ថុ គឺបានផ្តល់នូវព័ត៌មានដែលមានសារៈសំខាន់ និងមានប្រយោជន៍សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ។ ហើយរបាយការណ៍ហិរញ្ញវត្ថុ ក៏ជារបាយការណ៍មួយដែលមានសារៈប្រយោជន៍ខ្លាំងបំផុតនូវក្នុងដំណើរការនៃគណនេយ្យ ពីព្រោះរបាយការណ៍ហិរញ្ញវត្ថុ គឺជាមធ្យោបាយមួយនៅក្នុងទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ដើម្បីឱ្យគេកាន់តែមានចំណាប់អារម្មណ៍មកលើវា។

[40] https://www.wingbank.com.kh/km/about-wing/annual-report/( ទស្សនាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ )

### ៣.២.១ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២

**Balance Sheet Report for Year Ended 31-12-2022**

| ទ្រព្យសកម្ម | សម្គាល់ | ដុល្លារអាមេរិច | ពាន់រៀល |
|---|---|---|---|
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ-សុទ្ធ | 4 | 183,373,258 | 754,947,703 |
| ប្រាក់បញ្ញើតាមបទបញ្ញត្តិ | 5 | 30,513,028 | 125,622,136 |
| ឥណទាន និងបុរេប្រទានទៅអតិថិជន-សុទ្ធ | 6 | 363,457,095 | 1,496,352,860 |
| ការវិនិយោគលើមូលបត្របំណុល-សុទ្ធ | 7 | 2,013,107 | 8,287,962 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 27,465,720 | 113,076,369 |
| ទ្រព្យសកម្មអរូបិយ | 9 | 3,354,709 | 13,811,337 |
| ទ្រព្យ និងបរិក្ខារ | 10 | 13,942,196 | 57,400,021 |
